# ប្រវត្តិទីក្រុងពារាណសី

(ឯកសារសិក្សាស្រាវជ្រាវ)



ព្រះពុទ្ធរូបសម្តែងធម្មចក្រ នៅសម័យគុប្តៈ ស.វ.ទី៣

ព្រះសុមេធវង្ស **ញ៉ៀម គឹមតេង** (វជិរប្បញ្ញោ)

# ប្រវត្តិជីក្រុង៍ពារាណសី

ដោយ

ព្រះសុមេធវង្ស **ញៀម គឹមតេង** (វជិរប្បញ្ញោ)
បណ្ឌិតទស្សនវិជ្ជាពុទ្ធសាសនានៃសាកលវិទ្យាល័យញូដេល្លី, ឥណ្ឌា
ប្រធានផ្នែកពុទ្ធិកឧត្តមសិក្សា និងក្រោយពុទ្ធិកឧត្តមសិក្សា
នៃអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ, កម្ពុជា

សម្រាប់ចែកជាធម្មទាន

ព.ស. ២៥៥០ គ.ស.២០០៦

# មាតិកា


| ចំណងជើង | ទំព័រ |
|---|---|
| ១-ប្រវត្តិទីក្រុងពារាណសី | ៦ |
| ២-ឥសីបតនមិគទាយវ័ន | ១០ |
| ៣-ទីក្រុងសារនាថ | ១២ |
| ៤-បញ្ចវគ្គិយភិក្ខុ | ១៦ |
| ៦-ការបង្កើតសហគមន៍សង្ឃដំបូង | ១៨ |
| ៧-ឧបាសកឧបាសិកាដំបូង | ១៩ |
| ៨-ការរស់ឡើងវិញនៃតំបន់សារនាថ | ២១ |
| ៩-ធម្មរាជិកស្តូប | ២២ |
| ១០-សសរថ្មរបស់ព្រះបាទធម្មាសោក | ២៤ |
| ១១-ធម្មេតស្តូប | ២៦ |
| ១២-ចូក្ខណ្ឌីស្តូប | ២៩ |
| ១៣-មូលគន្ធកុដិ | ៣៣ |
| ១៤-អនាគារិកធម្មបាល | ៣៤ |
| ១៥-មូលគន្ធកុដិថ្មី | ៣៦ |
| ១៦-សំណង់ពុទ្ធសាសនាប្រទេសនានា និងសំណង់សាសនានានា | ៣៨ |

# អារម្ភកថា

កាលខ្ញុំនៅក្មេង, ខ្ញុំចូលចិត្តស្តាប់ចាប៉ីរឿង ច្រៀងដោយអ្នកចម្រៀងល្បីៗ ដែលធ្វើឲ្យខ្ញុំចងចាំបានយ៉ាងល្អនូវពាក្យពេចន៍ វគ្គឃ្លាខ្លះៗនៃបទចម្រៀងដូចជាឈ្មោះក្រុងពារាណសី ឬឈ្មោះនគរពារាណសីជាដើម ។ បន្ទាប់មកទៀត ខ្ញុំបានចូលបួសជាសាមណេរក្នុងពុទ្ធសាសនា ធ្វើឲ្យខ្ញុំបានស្គាល់ឈ្មោះក្រុង "ពារាណសី" កាន់តែច្បាស់ជាងមុនបន្តិច តាមរយៈការសិក្សាព្រះធម៌ឈ្មោះធម្មចក្កប្បវត្តនសូត្រ និងការអានរឿងជាតក បញ្ញាសជាតក និងទសជាតក៍ជាដើម ។ ពេលខ្ញុំបានចូលសិក្សាភាសាបាលី នៅសាលាពុទ្ធិកសិក្សា ខ្ញុំបានស្គាល់ទីក្រុងពារាណសី កាន់តែច្បាស់ជាងមុនថែមទៀត តាមរយៈការបកប្រែគម្ពីរធម្មបទជាដំបូង និងគម្ពីរនានាទៀតជាបន្តបន្ទាប់ ។ តែទោះបីម្ល៉េចម្ដា, ការស្គាល់ទីក្រុងពារាណសីរបស់ខ្ញុំកាលនោះ ស្ថិតនៅក្នុងក្តីស្រមៃត្រឹមជារឿងនិទានតែប៉ុណ្ណឹងឯង មិនដឹងថាទីក្រុងពារាណសីនោះនៅឯណាទេ ។ ពេលខ្ញុំបានទៅបន្តការសិក្សា ថ្នាក់អនុបណ្ឌិតទស្សនវិជ្ជាពុទ្ធសាសនា នៅសាកលវិទ្យាល័យញូដែល្ហី ប្រទេសឥណ្ឌា, ខ្ញុំបានចំណាយពេលទៅទីក្រុងបុរាណនេះ ដើម្បីនមស្សការនិងទស្សនាពុទ្ធស្ថាននានា ដែលមាននៅសេសសល់ទីនោះ ក្នុងអារម្មណ៍រំភើបក្រៃលែង ហាក់បីដូចជាបានទៅជួប និងបានថ្វាយបង្គំចំពោះព្រះពុទ្ធអង្គផ្ទាល់ ។ ខ្ញុំបានទៅទស្សនាទីក្រុងពារាណសីជាញឹកញាប់ណាស់ ដើម្បីនមស្សការព្រះសារីរិកធាតុរបស់ព្រះពុទធបរមគ្រូ និងពុទ្ធស្ថាននានាផងដែរ ។

ខណៈដែលកំពុងសិក្សានៅមហាវិទ្យាល័យ ខ្ញុំក៏បានស្រាវជ្រាវពីប្រវត្តិទីក្រុងនោះ និងព្រឹត្តិការនានាទៀតដែលទាក់ទង នឹងទីក្រុងពារាណសីនោះឯង ។ អត្ថបទជាភាសាខ្មែរ ដែលខ្ញុំបានសរសេរចេញ គិតថានឹងបោះពុម្ពនៅពេលណាមួយ ដើម្បីចែកជូនដល់អ្នកដែលពេញចិត្តក្នុងការអាន ។

ពត៌មាននៃទីក្រុងពារាណសី ដែលមាននៅក្នុងអត្ថបទនេះ ពុំទាន់គ្រប់គ្រាន់នៅឡើយទេ ខ្ញុំកំពុងតែស្រាវជ្រាវបន្តទៀត ហើយនឹងដាក់បញ្ចូលនៅក្នុងការបោះពុម្ពលើកក្រោយទៀត ។ ខ្ញុំបានឲ្យឈ្មោះសៀវភៅនេះថា "ប្រវត្តិទីក្រុងពារាណសី" យកតាមឈ្មោះទីក្រុងនេះតែម្តង ។

ខ្ញុំសង្ឃឹមថា សៀវភៅប្រវត្តិទីក្រុងពារាណសីនេះ អាចនឹងបានជាប្រយោជន៍មួយចំណែកធំ ដល់លោកអ្នកដែលមានបំណងចង់ស្វែងយល់ពីប្រវត្តិពុទ្ធសាសនា ពិសេសពីទំនាក់ទំនងរវាងព្រះពុទ្ធបរមគ្រូ ទៅនឹងទីក្រុងពារាណសីនេះឯង ។

សូមអភ័យទោសទុកជាមុន នូវរាល់កំហុសឆ្គងដោយអចេតនា ដែលមាននៅក្នុងសៀវភៅនេះ ។ សូមឧទ្ទិសស្នាដៃនេះ ជូនចំពោះឪពុករបស់ខ្ញុំដែលបានទទួលអនិច្ចកម្មទៅក្នុងឆ្នាំ១៩៩៨ និងម្តាយដែលមានជីពជន្មរស់នៅសព្វថ្ងៃ ព្រមទាំងលោកបណ្ឌិត ថោង ផែល និងគ្រួសារ ដែលមានគុណូបការៈចំពោះការសិក្សារបស់ខ្ញុំ ។

ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៦

# សេចក្តីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណ ចំពោះលោកឧបាសក **ស៊ាង លឹម** ដែលបានបញ្ចូលសៀវភៅនេះ ទៅក្នុងប្រព័ន្ធវេបសាយ ដើម្បីបង្ហោះចែកចាយជាធម្មទានជូនដល់អ្នកត្រូវការសិក្សា ។

សព្វថ្ងៃនេះ សម្ភារៈបច្ចេកវិជ្ជាទំនើបៗ ត្រូវបានគេស្រាវជ្រាវរកឃើញជាបន្តបន្ទាប់ ដើម្បីបម្រើសេចក្តីត្រូវការគ្មានទីបញ្ចប់របស់មនុស្ស ។ សម័យសាកលភាវូបនីយកម្ម ជាសម័យកាលមួយដែលពត៌មានវិទ្យា បានឈានមុខក្នុងការធ្វើឱ្យពិភពលោកនេះ បានក្លាយមកជាភូមិដ៏តូចមួយ លើវិស័យទំនាក់ទំនង ។ ខ្ញុំយល់ថាវេបសាយនេះ ជាបណ្ណាល័យដ៏មានសារៈសំខាន់ សម្រាប់ជួយដល់អ្នកត្រូវការសិក្សាស្រាវជ្រាវ លើចំណេះដឹងផ្នែកពុទ្ធសាសនា ។

សូមថ្លែងនូវការកោតសរសើរ លើការខិតខំប្រឹងប្រែង ជូនលោកឧបាសក **ស៊ាង លឹម** ក្នុងការបង្កើតឱ្យមានវេបសាយនេះឡើង ។

សូមជូននូវពុទ្ធពរ អាយុ វណ្ណៈ សុខៈ ពលៈ កើតមានគ្រប់ទិវារាត្រី ។

ថ្ងៃទី ១៥ ខែឧសភា ឆ្នាំ២០១៣

ព្រះសុមេធវង្ស បណ្ឌិត ញ៉ែម គឹមតេង (វជិរប្បញ្ញោ)

# ប្រវត្តិទីក្រុងពារាណសី

នៅក្នុងគម្ពីរអង្គុត្តរនិកាយ, សុត្តន្តបិដក បានបញ្ជាក់អំពីឈ្មោះមហាជនបទទាំង១៦ ដោយពិស្តារ[១] ។ កាសីជាឈ្មោះរដ្ឋមួយ ក្នុងចំណោមមហាជនបទទាំង១៦នោះ ។ មុនសម័យពុទ្ធកាល ដែនកាសីគឺជារាជាណាចក្រដ៏មានឥទ្ធិពលបំផុត, លុះមកដល់សម័យពុទ្ធកាល ដែននេះបានធ្លាក់មកនៅក្រោមការត្រួតត្រា របស់ស្ដេចបសេនទិ ជាព្រះរាជាដែនកោសលវិញ ។ ក្នុងមហាគោវិន្ទសូត្របានបញ្ជាក់ថា ព្រះបាទធតរដ្ឋៈគឺជាបឋមក្សត្រ នៃដែនកាសីនេះឯង ។ រាជធានីរបស់ដែនកាសី ឈ្មោះពារាណសី ដែលជាទីក្រុងមានអាយុកាល ចំណាស់ជាងគេនៅក្នុងទ្វីបអាស៊ីនេះ ។ ជាច្រើនពាន់ឆ្នាំមកហើយ ទីក្រុងពារាណសី មិនដែលមានការផ្លាស់ប្ដូរទីតាំងឡើយ ។ ក្នុងគម្ពីរជាតកបានរៀបរាប់ ពីឈ្មោះទីក្រុងពារាណសី ដែលត្រូវបានគេហៅតាមសម័យកាលនីមួយៗ ដូចជាហៅថា ទីក្រុងសុរុន្ធនៈ (ក្នុងឧទ្ទេយ្យជាតក), សុតសោណៈ, សោមានន្ទៈ, ផុស្សវតី, រមណគារៈ និង មុលិនី ជាដើម ។ នៅក្នុងចក្កវត្តិសីហនាទសូត្រ នៃគម្ពីរទីឃនិកាយ សុត្តន្តបិដក បានបញ្ជាក់ថា នៅពេលព្រះពុទ្ធសិអារ្យមេត្រីយ៍បានត្រាស់ដឹងឡើងក្នុងលោក នៅចុងកន្ទុយនៃភទ្ទកប្បនេះ ទីក្រុងពារាណសី

---

[១] មហាជនបទទាំង១៦នោះគឺៈ អង្គៈ, មគធៈ, កាសី, កោសល, វជ្ជី, មល្លៈ, ចេតី, វង្សៈ, កុរុ, បញ្ចាល, មាតស្យៈ, សុរសេនៈ, អនមាកៈ, អវន្តិ, គន្ធារៈ, កម្ពោជៈ។

នឹងមានឈ្មោះថាទីក្រុង”កេតុមតី” ដែលជាទីក្រុងមានការរុងរឿងក្រៃលែង និងមានមនុស្សម្នាយ៉ាងច្រើមកុះករ ។

ពួកប្រវត្តិវិទូមិនទាន់បានរកឃើញថា ទីក្រុងពារាណសីនេះមានអាយុកាលប៉ុន្មានសតវត្សមកហើយទេ ។ ទោះបីជាយ៉ាងនេះក្តី, តាមរយៈការធ្វើកំណាយគេសន្និដ្ឋានបានថា អ្នកស្រុកដើមបានមកតាំងទីលំនៅ លើទឹកដីក្រុងពារាណសីនេះ តាំងពីមួយពាន់ឆ្នាំមុនគ.ស.ម្ល៉េះ ។ ពួកជនជាតិអារ្យ៉ែនបានបង្កើតតំបន់នោះ ឲ្យក្លាយជាទីតាំងវប្បធម៏, សិក្សាអប់រំ, សេដ្ឋកិច្ច, និងសិប្បកម្មផ្សេងៗទៀត ។ ចាប់តាំងពីសម័យមោរ្យ៉ែន (សតវត្សទី៣-៤ មុនគ.ស.) រហូតដល់សម័យគុប្តៈ (សតវត្សទី៥-៦ នៃគ.ស.) ទីក្រុងពារាណសីត្រូវបានកត់ត្រាទុកថាជាទីក្រុងមានកេរ្តិ៍ឈ្មោះ ល្បីរន្ទឺនៅក្នុងទំព័រប្រវត្តិសាស្ត្រ ។ ភាពរុងរឿងនៃទីក្រុងពារាណសីបានឈានឡើងទៅដល់កំរិតកំពូល នៅក្នុងសម័យគាហាដាវាលៈ (Gahada vala period) (សតវត្សទី១១និងសតវត្សទី១២) ទើបទទួលការវាយឆ្មក់ចូលដោយពួកម៉ាហ៍មុដ (Mahmud) នៃកងទ័ពឃាស្និ (Ghazni) នៅឆ្នាំ១០៣៣ ។ នៅក្នុងគម្ពីរជាតកមានការរៀបរាប់ ពីនាមព្រះមហាក្សត្រជាច្រើនអង្គ ដែលទ្រង់បានគ្រប់គ្រងអំណាច នៅក្នុងទីក្រុងពារាណសីនោះជាបន្តបន្ទាប់ដូចជា ព្រះរាជានាម អង្គៈ, ឧគ្គសេនា, ឧទេយ្យៈ, កិកី, ធនញ្ជយៈ, មហាសីលវៈ និងព្រះរាជានាមវិស្សសេនាជាដើម ។ ព្រះរាជាគ្រប់ព្រះអង្គ ដែលបានគ្រប់គ្រងអំណាច

ក្នុងនគរនេះ ប្រហែលជាមានសន្តិវង្ស តមកពីព្រះបាទព្រហ្មទត្ត[២] ឬក៏ពាក្យថា"ព្រហ្មទត្ត"នេះ គឺជាបរមនាមរបស់ព្រះរាជា ក្រុងពារាណសី ។

ក្រុងពារាណសីតាំងនៅតាមបណ្ដោយដងទន្លេគង្គា (Ganga) ជាទន្លេដ៏ស័ក្តិសិទ្ធមួយ នៅក្នុងសាសនាហិណ្ឌូ ។ មុនសម័យពុទ្ធកាល គឺនៅរវាងសតវត្សទី៧មុនគ.ស. ទីក្រុងពារាណសី គឺជាមូលដ្ឋានយ៉ាងរឹងមាំនៃព្រហ្មញ្ញសាសនា, លុះមកដល់សម័យពុទ្ធកាល ព្រះពុទ្ធបានជ្រើសយកទីនោះ ជាទីតាំងធំមួយសម្រាប់ផ្សាយពុទ្ធសាសនា ទៅកាន់ទីស្ថាននានា ។ ទោះបីជាពុទ្ធសាសនាបានយកទីក្រុងពារាណសី ជាមជ្ឈមណ្ឌលផ្សាយសាសនាក៏ដោយ ក៏ទីក្រុងបូរាណនោះ នៅតែជាសាសនមណ្ឌលដ៏សំខាន់ របស់សាសនាហិណ្ឌូដដែល ។ ចាប់ពីសតវត្សទី១១នៃគ.ស.មក គឺនៅក្នុងរជ្ជកាលអធិរាជនាមមុឃល្ល: (Mughal Emperor) ព្រះរាជានាមអូរង្គសិប (Aurangzeb) ទ្រង់កាន់សាសនាឥស្លាមបានដឹកនាំពួកឥស្លាមសាសនិក វាយកំទេចចោលនូវវត្តអារាម និងសំណង់នានារបស់ពុទ្ធសាសនា និងសាសនាហិណ្ឌូ ដែលមាននៅទីនោះពីមុនមក ហើយបានកសាងវិហារឥស្លាមជំនួសវិញ ព្រមទាំងបានបង្ខំឲ្យអ្នកស្រុក ងាកទៅគោរពសាសនាឥស្លាមវិញ ។

---

[២] ស្ដេចនគរពារាណសី (អាចមាននគរផ្សេងទៀតដែរ) មានបរមនាមថា ព្រះបាទព្រហ្មទត្ត ពីព្រោះព្រះអង្គ ប្រើអាជ្ញាផ្ទាល់ ដែលហៅថាព្រហ្មទណ្ឌ ដើម្បីគ្រប់គ្រងលើប្រជារាស្ត្រ ។

ជាច្រើនសតវត្សបន្ទាប់មក សាសនាហិណ្ឌូក៏មានឥទ្ធិពល ទៅលើទីក្រុងពារាណសី ហេតុនេះទើបពាក្យថា “ពារាណសី” បានក្លាយជានិមិត្តរូបនៃការរស់រានឡើងវិញនៃសាសនាហិណ្ឌូ ។

ពួកអ្នកគោរពសាសនាហិណ្ឌូ តែងតែនាំគ្នាទៅមុជទឹកទន្លេគង្គា នៅពេលព្រឹកព្រលឹមជាប្រចាំ ពិសេសនៅពេលរដូវត្រជាក់ ដោយមានជំនឿថាការបានងូតទឹកទន្លេគង្គា អាចជួយឲ្យពួកគេជម្រះបាន នូវអំពើបាបទាំងឡាយទាំងពួងដែលគេបានប្រព្រឹត្តកន្លងមក ។ មិនត្រឹមតែប៉ុណ្ណោះទេ ទឹកទន្លេគង្គានេះ មានអានុភាពជួយឲ្យពួកគេ បានទៅកាន់ស្ថានសួគ៌បន្ទាប់ពីស្លាប់ទៅ ។ សាកសពមនុស្សស្លាប់ ត្រូវបានគេនាំយកទៅបូជានៅត្រើយទន្លេគង្គា, ពេលបូជាសពរួចគេនាំយកកំទេចឆ្អឹងដែលនៅសេសសល់ ទៅបាចសាចក្នុងទឹកទន្លេគង្គា សូម្បីតែធ្យូង ឬរបស់ដែលនៅសេសសល់ពីព្រះអគ្គី ក៏ត្រូវបានគេរុញទម្លាក់ចូលក្នុងទឹកទន្លេគង្គាទាំងអស់ដែរ ដើម្បីឲ្យព្រលឹង ឬអាត្ម័នរបស់អ្នកស្លាប់បានទៅ កាន់ស្ថានសួគ៌ ។

ក្រុងពារាណសីជាទីប្រជុំ នៃអ្នកចេះដឹងខាងភាសាសំស្ក្រឹត ពិសេសជាមជ្ឈមណ្ឌលបង្រៀនភាសាសំស្ក្រឹត ដែលមានមកទាំងពីបូរាណកាល, សូម្បីតែសព្វថ្ងៃនេះ ទីនោះក៏នៅតែជាមជ្ឈមណ្ឌលដ៏សំខាន់ នៃភាសាសំស្ក្រឹតដដែល ។ សព្វថ្ងៃទីក្រុងពារាណសី មានសាកលវិទ្យាល័យធំៗចំនួនពីកន្លែងគឺ សាកល

វិទ្យាល័យសំស្រ្កឹត (Sanskrit University) និងមួយទៀតគឺសាកលវិទ្យាល័យហិណ្ឌូពារាណសី (Benares Hindu University) ។

ពួកប្រវត្តិវិទូបានកត់ត្រាទុកមកថា បានជាទីក្រុងនេះមានឈ្មោះថា "ពារាណសី" ពីព្រោះទីក្រុងនេះឯង តាំងនៅត្រង់ចន្លោះដងស្ទឹងធំៗពីរ គឺស្ទឹង "វរុណៈ" និងស្ទឹង "អាសី" ។ ពីបូរាណទីក្រុងពារាណសី គឺជាមជ្ឈមណ្ឌលសេដ្ឋកិច្ច និងឧស្សាហកម្មដ៏សំខាន់មួយ បានធ្វើការផ្លាស់ប្តូរពាណិជ្ជកម្ម ដោយផ្ទាល់ជាមួយក្រុងសាវត្ថី (ស្ថិតនៅខាងជើង), ទីក្រុងតក្កសិលា (ស្ថិតនៅខាងលិច) កាត់តាមផ្លូវលំធំមួយឈ្មោះភទ្ទិយៈ ទៅកាន់ក្រុងរាជគ្រឹះ (ដែលស្ថិតនៅខាងកើត) និងមានផ្លូវគមនាគមន៍ជើងទឹក សម្រាប់ផ្លាស់ប្តូរទំនិញពាណិជ្ជកម្ម ជាមួយទីក្រុងកោសម្ពី ទីក្រុងបាដលីបុត្រ និងទីក្រុងវេសាលី ។

នៅក្នុងមិលិន្ទបញ្ហាបញ្ជាក់ថា សំពត់ដែលល្អជាងគេ គឺសំពត់ដែលត្បាញនៅដែនកាសី ដែលពួកឈ្មួញនាំយកទៅលក់ នៅសាកលនគររបស់ស្តេចមិលិន្ទ ។ ក្នុងនិទានជាតកមានបញ្ជាក់ផងដែរថា ទីក្រុងពារាណសីជាទីផ្សារលក់ខ្លឹមចន្ទន៍ក្រឹស្នា របស់របរកសិកម្ម សំពត់ល្អៗ គ្រឿងអលង្ការមាសពេជ្រ និងជាកន្លែងបង្ហាត់សេះ ដំរី ដ៏ប៉ិនប្រសព្វផងដែរ ។ ជាប្រពៃណី ពួកយុវជននៅក្រុងពារាណសី តែងនាំគ្នាទៅសិក្សាចំណេះវិជ្ជាផ្សេងៗ ពីសំណាក់អាចារ្យទិសាបាមោក្ខ នៅសាកលវិទ្យាល័យតក្កសិលា ។ ប៉ុន្តែនៅក្នុងសម័យនោះ ទី

ក្រុងពារាណសី ក៏ជាមជ្ឈមណ្ឌលបណ្តុះបណ្តាលសិល្បៈវិទ្យាមួយ មានឈ្មោះល្បីល្បាញសម្បើមណាស់ដែរ ។

បច្ចុប្បន្ននេះ ទីក្រុងងពារាណសីមានឈ្មោះថា “វ៉ារ៉ាណាស៊ី” (Varanashi) ឬទីក្រុង “បេណារេស” (Benares) ឬហៅថាទីក្រុង “កាសី” (Kashi) ស្ថិតនៅក្នុងរដ្ឋឧត្តរប្រទេស (Uttar Pradesh) ប្រទេសឥណ្ឌា ។ រដ្ឋឧត្តរប្រទេសមានផ្ទៃដីសារុប២៣៨,៥៦៦គ.ម.ក្រឡា មាន៧០ស្រុក និងមានប្រជាជនសារុប១៦៦,៥២០,៨៥៩នាក់ ដង់ស៊ីតេក្នុងមួយគីឡូម៉ែត្រក្រឡា ៦៨៩នាក់ ។

# ឥសីបតនមិគទាយវ័ន

ទីក្រុងសារនាថ (Sarnath) មានចម្ងាយ១០គ.ម. ស្ថិតនៅខាងជើងទីក្រុងពារាណសី ។ នៅទីនោះមានសំណង់ចាស់ជាច្រើន បានបន្សល់ទុកមកតាំងពីសម័យពុទ្ធកាល ដែលមានអាយុកាលជាង២៥០០ឆ្នាំមកហើយ ។ សព្វថ្ងៃនេះ ទីក្រុងតូចនេះ គឺជាមណ្ឌលដ៏សំខាន់បំផុតមួយ ចំណោមសំវេជនីយស្ថានធំៗទាំងបួនកន្លែងរបស់ព្រះពុទ្ធសាសនា ។

ពីបូរាណទីនោះមានឈ្មោះថា ឥសីបតនមិគទាយវ័ន ។ ឈ្មោះនេះផ្សំចេញពីពាក្យពីរម៉ាត់គឺៈ “ឥសីបតនៈ + មិគទាយវ័ន” ។ ពាក្យថា ឥសីបតនៈ មានន័យថា “ការធ្លាក់ចុះនៃពួកឥសី” ដោយមាននិទានក្នុងគម្ពីរមហាវស្តុ ជាភាសា

សំស្ក្រឹតថា នៅក្នុងពេលកន្លងយូរយារហើយ មានព្រះបច្ចេកពុទ្ធ៥០០អង្គ បាននិមន្តចូលទៅកាន់ទីព្រៃនោះ ដើម្បីគង់ចាំវស្សាតាមធម្មតានៃអ្នកបួស ។ នៅក្នុងការគង់ចាំវស្សាបីខែ ព្រះបច្ចេកពុទ្ធទាំង៥០០អង្គនោះ បានខិតខំប្រឹងប្រែងប្រតិបត្តិធម៌ រហូតដល់រូបកាយស្គាំងស្គម ដួលចុះលើផែនដី ទីបំផុតក៏សុគតទាំងអស់អង្គទៅ ។

ពាក្យបាលី "បតៈ" គឺជាកិរិយាស័ព្ទ ប្រែថា "ដួលចុះ" ឬក៏ "ធ្លាក់ចុះក្រោម" ។ ភាសាបាលីហៅអ្នកបួសដែលរស់នៅក្នុងព្រៃថា "ឥសី" ភាសាសំស្ក្រឹត ថា "ឫសី" ។ ដូច្នេះទីនោះក៏ត្រូវបានគេហៅថា "ឥសីបតនៈ ឬ "ឫសីបត្នៈ" តរៀងមក ។

ម្យ៉ាងវិញទៀត, ទីនោះមានព្រៃដុះទ្រុបទ្រុល ជាទីប្រជុំនៃរុក្ខជាតិជាច្រើនប្រភេទ មានអូរ មានដីទួល ដីទំនាប ដែលអំណោយផលល្អដល់សត្វព្រៃច្រើនប្រភេទ រស់នៅបានដោយសុខស្រួល, ពិសេសមានសត្វប្រើស ក្តាន់ ឈ្លូស និងសត្វចតុប្បាទឯទៀតៗ អាស្រ័យនៅដោយសុខសប្បាយ ។ ព្រះចៅក្រុងពារាណសី បានកំណត់យកទីព្រៃនោះ ជាឧទ្យានរបស់ព្រះរាជា, ទ្រង់បានហាមប្រាមពួកព្រានព្រៃ ក្នុងការចូលទៅបរបាញ់សត្វក្នុងព្រៃនោះ ដើម្បីរក្សាទុកសត្វចតុប្បាទទាំងនោះ ឲ្យរស់នៅប្រកបដោយសន្តិភាព ទើបទីនោះមានឈ្មោះមួយទៀតថា "មិគទាយវ័ន" ប្រែថា "ព្រៃឲ្យអភ័យដល់សត្វម្រឹគ" ។ ភាសាសំស្ក្រឹតបានហៅព្រៃនោះថា "ម្រិគទាយវ័ន" តរៀងមក ។

# ក្រុងសារនាថ

មានគម្ពីរជាតកមួយទៀតនិទានថា ក្នុងសម័យមួយ ព្រះពោធិសត្វនៃយើង បានកើតជាសត្វប្រើសមាសឈ្មោល មានឈ្មោះថា “សារង្គនាថ” ជាស្ដេចធំលើសត្វប្រើសទាំងឡាយ ដែលរស់នៅក្នុងព្រៃនោះឯង ។ នៅក្នុងព្រៃនោះ មានសត្វប្រើសពីរហ្វូងរស់នៅដោយឡែកពីគ្នា, ហ្វូងប្រើសមួយគ្រប់គ្រងដោយព្រះពោធិសត្វ និងហ្វូងប្រើសមួយក្រុមទៀត គ្រប់គ្រងដោយស្ដេចប្រើសទេវទត្ត, ហ្វូងនីមួយៗមានប្រើសប្រាំរយជាសមាជិក ។ គ្រាមួយនោះ ព្រះរាជាក្រុងពារាណសី បានយាងចូលក្នុងព្រៃដើម្បីប្រមាញ់សត្វប្រើស ។ ព្រះពោធិសត្វដែលកើតជាស្ដេចប្រើសមាស បានដើរចូលទៅរកព្រះរាជា រួចនិយាយចរចាថា “បពិត្រមហារាជ, សូមព្រះអង្គកុំដុតព្រៃជំរករបស់យើង, សូមកុំដេញបរបាញ់សម្លាប់ពួកយើង ដោយគ្រាប់ព្រួញធ្វើអ្វី នាំឲ្យខ្ទេចខ្ទាំសាច់ ហូរខ្សោះឈាម និងសោយទៅមិនឆ្ងាញ់ឡើយ ។ បើព្រះអង្គមានបំណងចង់សោយសាច់ប្រើសមែននោះ បន្ទាប់ពីអារុណរះឡើង យើងថ្វាយព្រះអង្គមួយថ្ងៃ នូវសត្វប្រើសមួយក្បាល ដើម្បីសម្លាប់ធ្វើជាម្ហូបសោយ ។

ព្រះរាជាមានព្រះទ័យរីករាយ នឹងសំណើនោះយ៉ាងក្រៃលែង ។ ប្រើសទាំងពីរហ្វូងនោះ បានដាក់វេនគ្នាមួយថ្ងៃម្នាក់ ដើម្បីជ្រើសយកប្រើសជាសមាជិករបស់ខ្លួន ទៅថ្វាយស្ដេចតាមពាក្យដែលបានសន្យាគ្នាមក ។ ការធ្វើដូច្នោះបានប្រព្រឹត្តទៅជារៀងរាល់ថ្ងៃ, នៅថ្ងៃមួយនោះ ក្នុងហ្វូងប្រើសដែលគ្រប់គ្រងដោយ

ទេវទត្ត បានជ្រើសយកប្រើសញីមួយក្បាល មានមាឌធំធាត់ និងមានផ្ទៃពោះផង ឲ្យចូលខ្លួនទៅថ្វាយស្ដេច ដើម្បីសម្លាប់ធ្វើជាម្ហូបព្រះស្ងោយ ។ ប្រើសញីនោះបានស្រែកអង្វរ និងយំរៀបរាប់ដោយសម្លេងខ្លាំងៗថា "លោកម្ចាស់ជាទីគោរព ! ថ្ងៃនេះ រូបខ្ញុំម្ចាស់ពិតជាស្លាប់ហើយ, សូមកុំឲ្យវេននៃការដើរចូលទៅរកសេចក្ដីស្លាប់នោះ កើតមានឡើងដល់កូនជាទីស្រឡាញ់របស់ខ្ញុំម្ចាស់ ដែលនៅក្នុងផ្ទៃឡើយ" ។ ស្ដេចប្រើសទេវទត្ត បានឮសម្ដីប្រើសញីទួញរៀបរាប់យ៉ាងនេះ មានសេចក្ដីក្រេវក្រោធយ៉ាងខ្លាំងតក្កមា ហើយបានស្រែកគំហកតបវិញថា "តើមាននរណាទៅដែលនិយាយថា ជីវិតគ្មានតម្លៃនោះ" ។ ប្រើសញីបានដកដង្ហើមយ៉ាងវែងរួចឆ្លើយថា "ឱលោកម្ចាស់ ! ព្រះរាជាគ្មានព្រះទ័យមេត្តាករុណាអាណិតអាសូរបន្តិចសោះ សម្លាប់សូម្បីតែសត្វដែលមិនទាន់បានកើតចេញមកផង" ។

ប្រើសញីទួញយំរៀបរាប់ប្រាប់ពីដំណើររឿងរបស់ខ្លួន ទៅដល់ប្រើសពោធិសត្វ ដែលមិនមែនជាស្ដេចនៃហ្វូងរបស់ខ្លួនឡើយ ។ បន្ទាប់ពីបានស្ដាប់ការយំរៀបរាប់មក, ប្រើសពោធិសត្វបាននិយាយថា "គួរឲ្យសង្វេគណាស់! ទឹកចិត្តរបស់ម្ដាយតែងតែស្រឡាញ់ និងកើតទុក្ខចំពោះកូនជានិច្ច សូម្បីតែកូនមិនទាន់ទាំងកើតចេញមកផង ។ ណ្ហើយចុះ ! ចូរនាងរស់នៅចុះ, ខ្ញុំស្ម័គ្រចិត្តទៅស្លាប់ជំនួសនាងវិញ" ។ ពោលរួចហើយ ប្រើសពោធិសត្វបានដើរសំដៅទៅរកទ្វារព្រះនគរដោយសេចក្ដីក្លាហានក្រៃលែង ។ មនុស្សម្នាធ្វើដំណើរទៅមកតាមផ្លូវបាននិយាយគ្នាថា ថ្ងៃនេះស្ដេចប្រើសមាសពោធិសត្វ បានចូលទៅកាន់ទីក្រុងហើយ ។ អស្ចារ្យណាស់! ចំជាអស្ចារ្យណាស់! ដំណឹងនេះបានឮដល់ព្រះរាជា

តែទ្រង់ពុំជឿឡើយ, ប៉ុន្តែនៅពេលដែលនាយទ្វារបាលនាំដំណឹងមកទូល ទើបព្រះអង្គជឿ ហើយទ្រង់បានយាងទៅជួបស្តេចប្រើសពោធិសត្វ ។ ប្រើសពោធិសត្វរៀបរាប់ថ្វាយព្រះរាជាថា "បពិត្រមហារាជ, មានប្រើសញីមួយមានផ្ទៃពោះនាងត្រូវវេនចូលមកស្លាប់ ដើម្បីថ្វាយសាច់ជាព្រះស្ងោយដល់ព្រះអង្គ, ប៉ុន្តែទឹកចិត្តរបស់ម្តាយ មិនអាចអត់ទ្រាំមិនគិតដល់កូនក្នុងផ្ទៃនោះបានឡើយ។ គួរឲ្យសង្វេគក្រៃលែង ទើបទូលបង្គំសម្រេចចិត្តចូលមកស្លាប់ជំនួសនាងវិញ ។ ស្តេចទ្រង់បាន សណ្តាប់ការរៀបរាប់ របស់ប្រើសពោធិសត្វហើយ ទ្រង់ក៏ដកដង្ហើមធំដែរ រួចមានបន្ទូលតបថា "ខ្ញុំមានរូបកាយជាមនុស្ស តែអន់ជាងសត្វ, ចំណែកអ្នកវិញមានរូបកាយជាសត្វប្រើសក៏ពិតមែន តែមានចិត្តជាមនុស្ស" ។ ចាប់ពីថ្ងៃនោះមក ព្រះរាជាទ្រង់ឈប់សម្លាប់សត្វ ហើយបានចេញបញ្ជាឲ្យរក្សាព្រៃនោះទុកជាទីរស់នៅនៃសត្វប្រើសនិងសត្វឯទៀតៗ រស់នៅជាសុខតរៀងមក ។

ដោយសារស្តេចប្រើសមាសពោធិសត្វ ឈ្មោះសារង្គនាថបានជួយសង្គ្រោះប្រើសញីមានផ្ទៃពោះ ឲ្យរួចជីវិតពីក្តីមរណាទាំងមេទាំងកូនក្នុងផ្ទៃ និងបានជួយជីវិតសត្វប្រើសទាំងពីរហ្វូងនោះ ឲ្យរួចផុតពីលក្ខខណ្ឌនៃសេចក្តីស្លាប់ផងដែរ, ទើបពាក្យថា "សារង្គនាថ" ដែលជាឈ្មោះរបស់ប្រើសមាសពោធិសត្វបានមកជាឈ្មោះតំបន់នោះ ។ ជាខាងក្រោយមក ពាក្យថា "សារង្គនាថ" ហៅក្លាយថា "សារនាថ" (Sarnath) រហូតមកដល់សព្វថ្ងៃនេះ ។

# បញ្ចវគ្គិយភិក្ខុ

ថ្ងៃ១៥កើត ពេញបូណ៌មី ខែពិសាខ ឆ្នាំរកា នៅទៀបគល់នៃមហាពោធិព្រឹក្សដ៏ឧត្តម ក្នុងឧរុវេលានិគម ជិតមាត់ស្ទឹងនេរញ្ជរា ដែនមគធៈ បច្ចុប្បន្នឈ្មោះពុទ្ធគយា ក្នុងស្រុកគយា រដ្ឋពីហារ៍[៣] ប្រទេសឥណ្ឌា ។ ក្រោយការបានត្រាស់ដឹងបាន៤៩ថ្ងៃមក ព្រះពុទ្ធអង្គបាននិមន្តចេញពីពុទ្ធគយា ដោយព្រះបាទាតែមួយព្រះអង្គឯង ក្នុងបំណងនាំយកព្រះធម៌ដែលទើបបានត្រាស់ដឹងថ្មីៗ ទៅសម្តែងប្រាប់ដល់អាឡារតាបសកាឡាមគោត្រ និងឧទកតាបសរាមបុត្រ ជាគ្រូធំដែលព្រះអង្គធ្លាប់បានស្នាក់រៀនសូត្រ នៅមុនពេលបានត្រាស់ដឹង, ប៉ុន្តែព្រះអង្គទ្រង់បានជ្រាបថា តាបសទាំងពីររូបនោះ បានទទួលអនិច្ចកម្មអស់ទៅហើយ ក៏ប្តូរព្រះទ័យនិមន្តឆ្ពោះ ទៅកាន់ព្រៃឥសីបតនមិគទាយវ័ន ក្រុងពារាណសីវិញ ដើម្បីសម្តែងធម៌ប្រាប់ដល់តាបសទាំងប្រាំអង្គ ដែលចេញបួសតាមព្រះអង្គ ។ តែដោយឃើញព្រះអង្គលះបង់ចោលនូវទុក្ករកិរិយា ហើយវិលមកឆាន់ចង្ហាន់ និងប្រព្រឹត្តតាមធម្មតាវិញ ក៏អស់ជំនឿលើការត្រាស់ដឹងរបស់ព្រះអង្គ ហើយនាំគ្នារត់ចោលព្រះសមណគោតម ទៅនៅក្នុងព្រៃឥសីបតនមិគទាយ័នវិញ ពីព្រោះទីនោះមានពួកឥសីជាច្រើនរស់នៅ ។ តាបសទាំងប្រាំរូបនោះមាន កោណ្ឌញ្ញៈ, វប្បៈ, ភទ្ទិយៈ, មហានទាម និងអស្សជិ ។

---

[៣] ពាក្យ ពីហារ៍ ក្លាយមកពីពាក្យ វិហារ (ផ្លាស់ វ ទៅជា ព) ។ សម័យពុទ្ធកាលគឺជាដែនមគធៈ មានរាជធានីឈ្មោះរាជគ្រឹះ, មកដល់ស្តេចអសោក ផ្លាស់រាជធានីមក បាដលីបុត្រ ។ ដោយស្តេចអសោក បានកសាងវិហារជាច្រើន ទើបដែនដីនោះមានឈ្មោះថា វិហារ ក្លាយទៅជា ពីហារ៍

មានរឿងតំណាលពីតាបសទាំងប្រាំរូបនោះមកថា តាបសឈ្មោះកោណ្ឌញ្ញៈជាព្រាហ្មណ៍ក្មេងជាងគេ ក្នុងចំណោមព្រាហ្មណ៍ទាំង៨រូប ដែលត្រូវបានជ្រើសរើសឲ្យទាយលក្ខណៈ ថ្វាយដល់ព្រះពោធិសត្វកុមារ ក្នុងពេលដែលព្រះអង្គទើបប្រសូតមកថ្មីៗ ។ ដោយការជឿជាក់ថា ព្រះកុមារពិតជាបានត្រាស់ដឹង ជាព្រះពុទ្ធមួយអង្គក្នុងលោក ក៏ស្ម័គ្រចិត្តចេញបួសតាមព្រះអង្គ ។ ចំណែកតាបសបួនរូបផ្សេងទៀត ជាកូនរបស់ព្រាហ្មណ៍ ដែលបានទាយលក្ខណៈថ្វាយព្រះអង្គដែរ តែខ្លួនមានវ័យចាស់ពេក មិនអាចរស់នៅទាន់ព្រះកុមារបានត្រាស់ដឹងជាព្រះពុទ្ធ ក៏បានផ្តាំកូនថាបើព្រះសិទ្ធត្ថកុមារ ចេញបួសឲ្យនាំគ្នាចេញបួសតាមព្រះអង្គកុំបីអាក់ខានឡើយ ។

ពេលព្រះសមណគោតម បានសម្រេចព្រះទ័យលះបង់ចោល នូវអត្តកលិមថានុយោគ គឺការបំពេញទុក្ករកិរិយាតឹងតែង ដែលជាការធ្វើខ្លួនឲ្យលំបាកឥតប្រយោជន៍ ហើយព្រះអង្គបានវិលត្រឡប់មកឆាន់ចង្ហាន់ និងប្រព្រឹត្តតាមប្រក្រតីវិញ, តាបសទាំងប្រាំនោះមានការអាក់អន់ចិត្ត និងអស់សង្ឃឹម ក៏នាំគ្នារត់ចោលព្រះអង្គ គេចខ្លួនទៅរស់នៅក្នុងព្រៃឥសីបតនមិគទាយវ័ន ទៀបក្រុងពារាណសី ។ ពេលបានដំណឹងថា ព្រះពុទ្ធអង្គនិមន្តទៅដល់ព្រៃឥសីតបនមិគទាយវ័នហើយ តាបសទាំងប្រាំរូបនោះ ក៏បានចេញទៅទទួលស្វាគមន៍ព្រះអង្គ ដោយសេចក្តីនឹករលឹកក្រៃលែង នៅឆ្ងាយពីកន្លែងដែលពួកខ្លួនរស់នៅ ហើយបាននិមន្តព្រះពុទ្ធអង្គ ទៅគង់នៅកន្លែងដ៏សមគួរមួយ ដែលពួកខ្លួនរៀបចំបំរុងទុកមុនជាស្រេច។

ព្រះពុទ្ធបាននិមន្តដល់ព្រៃឥសីបតនមិគទាយវ័ន នៅក្នុងថ្ងៃ១៥កើត ពេញបូណ៌មី ខែអាសាឍ ។ នៅក្នុងព្រៃឥសីបតនមិគទាយវ័ន ព្រះអង្គបានសម្ដែងធម៌ទេសនា ប្រោសតាបសទាំងប្រាំរូបនោះ ឲ្យបានសម្រេចនូវមគ្គផលតាមលំដាប់ឧបនិស្ស័យគ្រប់ៗគ្នា ហើយបានបំបួសតាបសទាំងប្រាំរូបនោះ ជាឯហិភិក្ខុតាមលំដាប់លំដោយ ទើបមានឈ្មោះថា "បញ្ចវគ្គីភិក្ខុ" កើតឡើង ដែលមានន័យថា "ក្រុមភិក្ខុមានគ្នាប្រាំនាក់" ។

# ការបង្កើតសហគមន៍សង្ឃដំបូងបំផុត

ព្រះពុទ្ធទ្រង់បានគង់ចាំព្រះវស្សាលើកដំបូងបំផុត នៅក្នុងព្រៃឥសីបតនមិគទាយវ័ន ជាមួយនឹងបញ្ចវគ្គិយភិក្ខុ ។ នៅទីនោះ ព្រះអង្គបានបំបួសយសកុលបុត្រ ជាកូនរបស់សេដ្ឋីនៅក្រុងពារាណសី និងសម្លាញ់របស់យសកុលបុត្រចំនួន៥៤នាក់ទៀត ។ ក្រោយបានបំបួសយុវជនទាំងអស់នោះហើយ ព្រះអង្គបានសម្ដែងធម៌វិន័យ ប្រៀនប្រដៅដល់ភិក្ខុថ្មីៗទាំងនោះ រហូតបានសម្រេចជាព្រះអរហន្តទាំងអស់អង្គទៅ ។ ក្នុងពេលនោះ មានព្រះអរហន្តចំនួន៦១អង្គក្នុងលោក រួមទាំងព្រះពុទ្ធអង្គផង ។

នៅក្នុងព្រៃឥសីបតនមិគទាយវ័ន ព្រះពុទ្ធអង្គទ្រង់បណ្ដុះបណ្ដាល បានព្រះសង្ឃចំនួន៦០អង្គ ដែលជាព្រះអរហន្ត (ព្រះសង្ឃជាបញ្ញវ័ន្ត) មានសមត្ថភាពគ្រប់គ្រាន់ ក្នុងការផ្សព្វផ្សាយសាសនា ទៅកាន់បរិស័ទគ្រប់ទិសទី ។ ក្រោយ

ការចេញព្រះវស្សាភ្លាម ព្រះពុទ្ធបានធ្វើពុទ្ធប្រកាសមួយ ដល់ព្រះសាវ័កទាំង៦០ អង្គនោះ ដែលមានខ្លឹមសារថា:

ចរថ ភិក្ខវេ ចារិកំ ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ មា ឯកេន ទ្វេ អគមិត្ថ ទេសេថ ភិក្ខវេ ធម្មំ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេថ សន្តិសត្តា អប្បរជក្ខជាតិកា អស្សវនតា ធម្មស្ស បរិហាយន្តិ ភវិស្សន្តិ ធម្មស្ស អញ្ញាតរោ ។[៤]

ប្រែថា ម្នាលភិក្ខុទាំងឡាយ, អ្នកទាំងឡាយចូរត្រាច់ទៅកាន់ចារិក (គឺស្រុក និគម រាជធានី ហើយសម្តែងធម៌), ដើម្បីជាប្រយោជន៍ និងសេចក្តីសុខដល់ជនជាច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីជាប្រយោជន៍ ដើម្បីជាគុណ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ, អ្នកទាំងឡាយកុំទៅពីរនាក់តាមផ្លូវតែមួយជាមួយគ្នាឡើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរសម្តែងធម៌ឲ្យពិរោះបទខាងដើម បទកណ្តាល និងបទខាងចុង, អ្នកទាំងឡាយ ចូរប្រកាសនូវព្រហ្មចរិយធម៌ដ៏បរិសុទ្ធ ប្រកបដោយអត្ថៈនិងព្យញ្ជនៈ ដ៏ពេញបរិ

---

[៩] មាននៅក្នុងមហាវគ្គ វិន័យបិដក ។

បូណ៌ទាំងអស់ ។ សត្វទាំងឡាយដែលមានធូលីគឺរាគាទិក្កិលេសតិច ក្នុងភ្នែកក៏មាន, សត្វទាំងនោះនឹងសាបសូន្យ (ចាកមគ្គផល) ព្រោះមិនបានស្តាប់ធម៌ សត្វទាំងឡាយដែលបំរុងនឹងត្រាស់ដឹងធម៌ក៏គង់នឹងមាន ។

# ឧបាសកឧបាសិកាដំបូងបំផុត

ពេលបានដឹងថាយសកុលបុត្របាត់ខ្លួន ដោយគ្មានបានប្រាប់ដំណឹងមាតាបិតារបស់យសកុលបុត្រ មានចិត្តរន្ធត់និងសោកសង្រេងក្រៃលែង បានប្រកាសដំណឹង និងចាត់អ្នកបំរើឲ្យចេញគ្រប់ច្រកល្ហក ដើម្បីស្វែងរកយសកុលបុត្រជាកូន ។ មិនយូរប៉ុន្មាន បិតារបស់យសកុលបុត្រ បានទៅដល់ព្រៃឥសីបតនមិគទាយវ័ន មានចម្ងាយ១០គ.ស. ពីទីក្រុងពារាណសី ជាកន្លែងដែលព្រះពុទ្ធអង្គកំពុងសម្តែងធម៌ទេសនា ក្នុងពេលបច្ចូសសម័យមុនអរុណោទ័យរះឡើង ហើយបានទូលសួរព្រះពុទ្ធ ពីការបាត់យសកុលបុត្រជាកូនរបស់ខ្លួន ។ តាមពិត យសកុលបុត្រកំពុងស្តាប់ធម៌ទេសនា នៅក្នុងទីនោះដែរ តែព្រះពុទ្ធអង្គទ្រង់បានប្រើពុទ្ធានុភាព មិនឲ្យឪពុកនិងកូនមើលឃើញគ្នា តាមភ្នែកធម្មតាឡើយ ដើម្បីញ៉ាំងចិត្តអ្នកទាំងពីរឲ្យស្ងប់នៅក្នុងព្រះធម៌ ។ ទីបំផុតសេដ្ឋីជាបិតារបស់យសកុលបុត្របានតម្កល់នៅក្នុងព្រះធម៌ បានថ្វាយខ្លួនជាឧបាសកដំបូងគេ ដល់នូវព្រះត្រៃសរណគមន៍ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាទីពឹង ទីរលឹកស្មើដោយជីវិត ។ លុះថ្ងៃស្អែកឡើង ព្រះបរមសាស្តានិងព្រះយសត្ថេរ បាននិមន្តទៅកាន់គេហដ្ឋាន

របស់សេដ្ឋី ដែលជាបិតាព្រះយសដើម្បីទទួលភត្ត បន្ទាប់មកព្រះអង្គទ្រង់បានសម្ដែងធម៌ទេសនាពីអនុបុព្វីកថា មានទានកថា សីលកថាជាដើម និងអរិយសច្ចៈទាំងបួន ញ៉ាំងស្ត្រីជាមាតានិងភរិយារបស់យសកុលបុត្រ ឲ្យមានសេចក្ដីជ្រះថ្លា និងមានចិត្តតាំងស៊ប់នៅក្នុងព្រះធម៌ឥតងាករេ ។ ស្ត្រីទាំងពីរបានពោលសរសើរ ព្រះធម៌ទេសនាយ៉ាងក្រៃលែង ហើយបានប្រកាសថ្វាយខ្លួនជាឧបាសិកាដល់នូវព្រះត្រៃសរណគមន៍ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងទីរលឹក មុនដំបូងគេបង្អស់ ក្នុងព្រះពុទ្ធសាសនា(៥) ។

# ការរស់ឡើងវិញនៃតំបន់សារនាថ

សារនាថ ជាមជ្ឈមណ្ឌលដ៏សំខាន់មួយរបស់ពុទ្ធសាសនា ត្រូវបានរកឃើញវិញ នៅក្នុងឆ្នាំ១៧៩៤ ដោយក្រុមបុរាណវិទូ ។ ស្ដេចទេវ័នជគាតសិង្ហ (Deanjagate Signh) ជាមហាក្សត្រគ្រងអំណាចនៃដែនកាសី បានបញ្ជាឲ្យវាយកំទេចចោលនូវធម្មរាជិកស្តូប ដែលជាស្តូបធំបំផុត និងជាទីគោរពរបស់ពុទ្ធសាសនិកជន នៅក្នុងតំបន់សារនាថនោះ ហើយទ្រង់ឲ្យនាំយកឥដ្ឋទៅកសាងសំណង់ផ្សេង នៅទីក្រុងពារាណសីវិញ ។ ព្រះរាជាអង្គនេះបានបញ្ជាឲ្យរុះរើ

---

(៥) អ្នកខ្លះយល់ថា មាតាយសកុលបុត្រឈ្មោះសុជាតា ជាស្ត្រីដែលបានថ្វាយមធុបាយាសដល់ព្រះសមណគោតម នៅមុនពេលព្រះអង្គបានត្រាស់ដឹង ។ តាមពិត នាងសុជាតាដែលបានថ្វាយមធុបាយាសនោះ ជាកូនសេនកុដុម្ពីក៍ នៅសេនានិគម សព្វថ្ងៃហៅថាស្រុកគយារដ្ឋពីហារ៍ មានចម្ងាយជាង២៥០គ.ស. ពីក្រុងពារាណសី ។

ស្តូបបូរាណចោល ដោយគ្មានព្រះទ័យគិតពិចារណាវែងឆ្ងាយឡើយ ។ ក្រុមអ្នករុះរើស្តូបបានប្រទះឃើញ ព្រះសារីរិកធាតុព្រះពុទ្ធអង្គ នៅក្នុងកោដ្ឋថ្មតូចមួយ ដែលដាក់នៅក្នុងកោដ្ឋថ្មធំមួយទៀត ។ ផ្នែកខ្លះនៃស្តូបនោះ ត្រូវបានគេនាំទៅរក្សាទុកនៅសារមន្ទីរជាតិ នៅក្នុងទីក្រុងសារនាថសព្វថ្ងៃនេះ ។

លោកជនត្ថាន-ឌុនខែន (Jonathan Duncan) បេសជនអង់គ្លេសប្រចាំនៅទីក្រុងពារាណសី បានបោះពុម្ពផ្សាយយ៉ាងពិស្តារ នូវស្នាដៃភាគទី៥ ដែលលោកបានស្រាវជ្រាវរកឃើញ នៅក្នុងឆ្នាំ១៧៩៨ ។ ការគាស់កាយរបស់ក្រុមបូរាណវិទូ បានបន្តរុករកនៅតំបន់សារនាថនោះ ជាច្រើនដងមកទៀត ក្រោមការត្រួតពិនិត្យយ៉ាងហ្មត់ចត់ របស់អ្នកប្រាជ្ញធំៗផ្នែកបូរាណវិទូ ។

# ធម្មរាជិកស្តូប

ធម្មរាជិកស្តូបកសាងឡើង ដោយព្រះបាទធម្មាសោក រវស់ឆ្នាំ២៤៥ មុនគ.ស. សម្រាប់តម្កល់ព្រះសារីរិកធាតុរបស់ព្រះពុទ្ធ ។ តាមរយៈការគាស់កាយជាលើកទីពីរ មិនបានឃើញព្រះសារីរិកធាតុព្រះពុទ្ធទេ ពីព្រោះជាក់ស្តែងនៅឆ្នាំ១៧៩៤ ស្តេចទេវ័នជគាស៊ិង្ហ (Devan Jagat Signh) នៃដែនកាសីបានឲ្យគេវាយស្តូបបំបែក ដើម្បីយកឥដ្ឋទៅកសាងផ្សារ នៅឯទីក្រុងពារាណសីវិញ ។ នៅពេលជីករំលើងស្តូបនោះបានជំរៅ៨,២៥ម៉ែត្រ, គេបានប្រទះឃើញកោដ្ឋថ្មមូលធំមួយ ដែលមានតម្កល់ព្រះសារីរិកធាតុព្រះពុទ្ធ មានក្នុងកោដ្ឋ

ធំនោះ មានកោដ្ឋថ្មតូចមួយទៀត មានដាំគុជខ្យងនិងទ្រាប់ដោយមាសសន្លឹក និងត្បូងពេជ្រជាច្រើនគ្រាប់ ។ ដោយយល់ថា ព្រះសារីរិកធាតុរបស់ព្រះពុទ្ធជាអព្វមង្គល ស្តេចទេវ៍នជគាតសិង្ហបានឲ្យគេនាំយកព្រះសារីរិកធាតុ ដែលបានបញ្ជាឲ្យយកព្រះធាតុ ដែលបានកាយរកឃើញនោះ ទៅបាចសាចនៅក្នុងទន្លេគង្គានៅពេលនោះទៅ ។ កោដ្ឋថ្មតូចនោះបានបាត់ទៅហើយ ឯចំណែកកោដ្ឋថ្មធំវិញ ក្រោយមកគេនាំយកទៅទុកនៅសារមន្ទីរជាតិ នៅក្រុងកាល់កូតា ។ សិលាចារិកមួយផ្ទាំងទៀត ក្នុងរជ្ជកាលស្តេចមហិបាល ឆ្នាំ១០២៦ ត្រូវបានរកឃើញនៅក្នុងបរិវេណដំណាក់ របស់ស្តេចទេវ៍នជគាតសិង្ហ ។

ធម្មរាជិកស្តូបនេះ ត្រូវបានកសាងឡើងវិញម្តងទៀត ក្នុងរជ្ជកាលស្តេចកុសាន នៅសតវត្សទី៦គ.ស. ហើយបន្តកសាងបន្ថែមទៀតនៅសតវត្សទី៧ ។ មហិបាលជាស្តេចនៃប្រទេសបឹងហ្គាល់ និងស្តេចគហឌាវល: (Gahadawala) ព្រមទាំងអគ្គមហេសីកុមារទេវី បានឧបត្ថម្ភការជួសជុលធម្មរាជិកស្តូបនេះ ។ វត្ថុបូរាណទាំងឡាយ ដែលបានរកឃើញជុំវិញស្តូបនោះមាន:

១-រូបបដិមាព្រះពោធិសត្វ មានកំពស់២,៨៥ម៉ែត្រ ជាទម្រង់អភយមុទ្រ:

២-រូបព្រះពុទ្ធបដិមាទ្រង់ឈរ មានកំពស់១.៣០ម៉ែត្រ ជាទម្រង់អភយមុទ្រ: រចនាបថក្នុងសម័យរាជវង្សគុប្ត: ។

៣-រូបពុទ្ធបដិមាមួយទៀត មានកំពស់១.៦០ម៉ែត្រ, ទ្រង់សំដែងធម៌ទេសនា ជារចនាបថសម័យគុប្តៈ មានរង្វង់ត្របកផ្កាឈូកព័ទ្ធជុំវិញ, ជារូបបដិមាដ៏ល្អបំផុត ដែលគេបានរកឃើញនៅក្នុងបរិវេណតំបន់សារនាថ ។

នៅក្បែរនោះមានរូបពុទ្ធបដិមាមួយទៀត ដែលគេបានប្រទះឃើញ គឺមានកំពស់០,៦៦ម៉ែត្រ អមដោយព្រះសិអារ្យមេត្រីយ៍ និងរូបព្រះអវលោកេតិស្វរៈ, រូបបដិមានេះប្រហែលជាកសាងនៅក្រោយសម័យគុប្តៈ ។ នៅក្បែរនោះដែរ មានសិលាចារិកមួយផ្ទាំងទៀត ប្រហែលជាសរសេរឡើង ក្នុងសតវត្សទី៨ ដែលមានសេចក្តីថា:

យេ ធម្មា ហេតុប្បភវា ហេតុំ តេសំ តថាគតោ អហ
តេសញ្ច យោ និរោធោ ច, ឯវំ វាទី មហាសមណោ ។

ប្រែថា: ធម៌ទាំងឡាយឯណាដែលកើតចេញពីហេតុ ព្រះតថាគតតែងពោលនូវហេតុនៃធម៌នោះ, ម្យ៉ាងវិញទៀតសេចក្តីរលត់ និងឧបាយឯណាជាគ្រឿងរលត់នៃធម៌នោះ, ព្រះតថាគតបានពោលហើយនូវសេចក្តីរលត់នោះ ។ ព្រះមហាសមណៈមានប្រក្រតីពោលពាក្យយ៉ាងនេះឯង ។

## សសរថ្មរបស់ព្រះចៅអសោក

ស្តេចអសោកបានកសាងសសរថ្ម ផ្ទាំងសិលាចារិកនិងស្តូប ចំនួន ៨៤,០០០ ដើម្បីឧទ្ទិសចំពោះព្រះពុទ្ធដែលបានសំដែងព្រះធម៌ មានចំនួន៨៤,

០០០ព្រះធម្មក្ខ័ន្ធ ។ ព្រះបាទអសោកបានប្រារព្ធធ្វើពិធីបុណ្យឆ្លងស្តូប ទាំង ៨៤,០០០ និងសមិទ្ធិផលទាំងអស់ របស់ព្រះអង្គដែលបានកសាង នៅថ្ងៃ១៥ កើត ពេញបូណ៌មី ខែកត្តិក ។ សសរស្តម្ភរបស់ព្រះបាទអសោក ស្ថិតនៅខាងលិច ជាប់នឹងមូលគន្ធកុដិ, សព្វថ្ងៃសសរថ្មនោះបាក់បែក នៅសល់ប្រវែង ២,១ម៉ែត្រប៉ុណ្ណោះ ។ នៅលើកំពូលសសរថ្ម មានរូបក្បាលសត្វរាជសីហ៍បួន បែរមុខទៅកាន់ទិសខុសៗគ្នា រូបនេះត្រូវបានរក្សាទុកនៅក្នុងសារមន្ទីរជាតិសារនាថ នៅជុំវិញសសរថ្មមានរូបធម្មចក្រ ។ សសរថ្ម និងរូបរាជសីហ៍ ត្រូវបានគេរកឃើញនៅក្នុងឆ្នាំ១៩០៤ ។

សសរថ្មនេះបានចែកចេញជា ៤ លក្ខណៈសំខាន់ៗគឺ:

១-ជើងខាងក្រោមទ្រទ្រង់បកផ្កាឈូក ផ្កាប់ចុះក្រោម ។

២-ផ្នែកជុំវិញមានរូបធម្មចក្រ៤ និងសត្វចតុប្បាទប្រភេទខុសគ្នាគឺ: រាជសីហ៍១, ដំរី១, គោឈ្មោល១, និងសេះអស្សតរ១ ។

៣-ខាងលើមានសត្វរាជសីហ៍បួនអង្គុយទល់ខ្នងគ្នា បែរមុខទៅកាន់ទិសទាំងបួន ។

៤-នៅកំពូលខាងលើ មានរូបធម្មចក្រដែលមានកាំ៣២ ។

នៅសសរថ្មមានអក្សរចារិកបីបន្ទាត់ ជាអក្សរព្រាហ្មី ដែលបានចារិកដោយព្រះបាទធម្មាសោក មានខ្លឹមសារថា “អធិរាជផែនដី សូមឲ្យដំបូន្មានដល់ព្រះសង្ឃនិងសីលវតីទាំងឡាយ ដែលបានប្រព្រឹត្តផ្ទុយពីធម៌វិន័យ ដែលបង្កើត

ឲ្យមានទំនាស់ក្នុងសហគមន៍សង្ឃ” ។ ខ្លឹមសារបន្ទាត់ទីបី គឺការដាស់តឿនរបស់ព្រះអធិរាជ ដែលមានខ្លឹមសារថា “គ្មានបុគ្គលណាមួយអាចបំបែកនិកាយ របស់សហគមន៍សង្ឃបានឡើយ” ។ ខ្ញុំសូមលើកយកព្រះរាជប្រកាសទីមួយ របស់ព្រះបាទធម្មាសោក ក្នុងទម្រង់អក្សរព្រាហ្មីមកប្រែជាភាសាខ្មែរ មានសេចក្ដីទាំងស្រុងដូចខាងក្រោម៖

“ព្រះសង្ឃនិងសីលវតីទាំងឡាយណា ដែលបង្កើតទំនាស់ក្នុងជួរសង្ឃ ឬថ្កោលទោសដល់សង្ឃ នឹងត្រូវឲ្យស្លៀកដណ្ដប់(សំពត់)ពណ៌-ស ហើយបណ្ដេញចេញពីសហគមន៍សង្ឃ” ។

ព្រះរាជប្រកាសទីពីរ ត្រូវបានធ្វើឡើងនៅក្នុងរជ្ជកាលព្រះបាទកុសនា ដែលសរសេរឡើងក្នុងឆ្នាំទី៤០ នៃអស្វឃោសៈ ។ ព្រះរាជាអង្គនេះគ្រងអំណាចនៅកោសម្ពី តែទ្រង់ជាប់ព្រះទ័យទៅរកតំបន់សារនាថយ៉ាងក្រៃលែង ។ ព្រះរាជប្រកាសទីបី ត្រូវបានចារិកឡើងនៅក្នុងយុគសម័យគុប្តៈដែរ ដែលរៀបរាប់បញ្ជាក់ពីអាចារិយៈ(គ្រូ)ទាំងឡាយ របស់សម្មតិយសិក្ខៈ ឬសម្មតិយនិកាយ និងវស្សិកបុត្តកនិកាយ ។

## ធម្មេកស្តូប

ធម្មេកស្តូប ជាស្តូបមួយដែលមានឈ្មោះល្បីល្បាញ នៅក្នុងពិភពពុទ្ធសាសនា ។ ស្តូបនេះមូលតាន់មានរាងដូចស្គរ មានវិជ្ឈមាត្របាតក្រោម ៣៣,៥៣ម៉ែត្រ, វិជ្ឈមាត្រខាងលើ២៨,៥០ម៉ែត្រ និងកំពស់៤២.០៦ម៉ែត្រ

រាប់ទាំងគ្រឹះក្រោមបញ្ចូលផង ។ ស្តូបនេះរក្សាទម្រង់ដើមទាំងស្រុង ទោះបីជាពេលវេលាបានកន្លងទៅ យូរលង់ណាស់ហើយក៏ដោយ ។ ពាក្យថា “ធម្មេកៈ” ពិតជាចេញមកពីពាក្យថា “ធម្មចក្រៈ” ឬ “ធម្មចក្កៈ” រួចហើយក៏ក្លាយជា “ធម្មក្កៈ” ចុងក្រោយក៏បានទៅជា “ធម្មេកៈ” ។ សិលាចារិកនៅសតវត្សទី១២ បានសរសេរថា ...ធម្មក្ក ជយតុ ... ដែលមានន័យថា “សូមឲ្យធម្មកៈតាំងនៅអស់កាលដ៏យូរ” ។ តាមសិលាចារិកនេះបញ្ជាក់ថា ស្តូបនេះត្រូវបានគេហៅថាធម្មកស្តូប តាំងពីសតវត្សទី១២មកម្ល៉េះ ។ លោកឧត្តមសេនីយ៍កុននីងហាំ បានឲ្យគេលុងកកាយចូលទៅត្រង់កណ្តាលស្តូប ដោយចង់ដឹងថាតើមានអ្វីខ្លះនៅខាងក្នុង ក៏បានប្រទះឃើញស្តូបបូរាណ ដែលកសាងក្នុងរជ្ជកាលរាជវង្សមោរ្យៈ ជាចេតីយ៍ដែលកសាងដំបូងបំផុត ដោយព្រះបាទធម្មាសោក ត្រង់កន្លែងព្រះពុទ្ធសម្តែងធម្មចក្កប្បវត្តនសូត្រ ប្រោសបញ្ចវគ្គិយភិក្ខុទាំងប្រាំអង្គ ។

ទោះបីធម្មេកស្តូបនោះធំមហិមា ហើយមិនមានការពណ៌នាណាមួយបញ្ជាក់ប្រាប់ឲ្យបានច្បាស់ក្តី ក៏សិលាចារិកនៅសតវត្សទី៦និងទី៧ ដែលគេបានរកឃើញ នៅក្រោមកំពូលខាងលើ មានសេចក្តីបញ្ជាក់ដូចខាងក្រោមៈ

យេ ធម្មា ហេតុប្បភវា ហេតុំ តេសំ តថាគតោ
តេសញ្ច យោ និរោធោ ច, ឯវំ វាទី មហាសមណោ ។

ប្រែថា ធម៌ទាំងឡាយឯណាដែលកើតចេញពីហេតុ ព្រះតថាគតតែងពោលនូវហេតុនោះ, ម្យ៉ាងវិញទៀត សេចក្តីរលត់និងឧបាយឯណាជាគ្រឿង

រលត់នៃធម៌នោះ, ព្រះតថាគតបានពោលហើយនូវសេចក្ដីរលត់នោះ ។ ព្រះមហាសមណៈ មានប្រក្រតីពោលពាក្យយ៉ាងនេះឯង ។



ធម្មេកស្តូបមានកំពស់៤២,០៦ម៉ែត្រ សាងឡើងដោយស្ដេចធម្មាសោក ត្រង់កន្លែង ព្រះពុទ្ធបរមគ្រូ សំដែងបឋមទេសនាប្រោសបញ្ចវគ្គីយភិក្ខុ នៅក្នុងតំបន់សារនាថ

# ចូក្ខណ្ឌីស្តូប

ពេលធ្វើដំណើរពីទីក្រុងពារាណសី ទៅសារនាថ យើងពិតជាបានឃើញស្តូបមួយទៀត ស្ថិតនៅខាងឆ្វេងដៃ ជាប់នឹងផ្លូវដែលយើងកំពុងធ្វើដំណើរ,ស្តូបនោះមានឈ្មោះថាចូក្ខណ្ឌី ។ ហេតុអ្វីបានជាគេហៅស្តូបនោះថា ចូក្ខណ្ឌីយ៉ាងនេះ? តាមន័យអក្សរសាស្ត្រពាក្យថា "ចូក្ខណ្ឌី" ប្រែថា "មានជ្រុងបួន" តែតាមពិតជាក់ស្តែង ស្តូបនេះមានជ្រុងប្រាំបី គួរតែត្រូវបានហៅថា "អដ្ឋកខណ្ឌី" ទៅវិញទើបស័ក្តិសមជាង ដែលប្រែថាមានជ្រុងប្រាំបី ។ ស្តូបនេះសង់ឡើងពីឥដ្ឋនិងកំបោរ ខ្ពស់ត្រដែតត្រង់ទៅលើ កំពូលខាងលើមានរាងជាអដ្ឋកោណ ។ ហ៊្វិន-ត្សាង អ្នកប្រវត្តិវិទូចិនបានទៅដល់ទីនោះ កាលពីសតវត្សទី៧ បានកត់ត្រាទុកថាគាត់បានឃើញស្តូបនេះមានកំពស់៣០០ហ្វីត ។ តាមរយៈកំណត់ត្រានេះយើងអាចសន្និដ្ឋានបានថា ព្រះពុទ្ធបានជួបតាបសទាំងប្រាំរូប ជាដំបូងត្រង់ទីនោះឯងដោយឥតសង្ស័យ ។ ហ៊្វិន-ត្សាង បានរៀបរាប់ទៀតថា ស្តូបនោះជាស្តូបដ៏ខ្ពស់បំផុត នៅក្នុងតំបន់សារនាថ ។

ជាច្រើនសតវត្សក្រោយមកទៀត ស្តូបនោះត្រូវបានបំផ្លាញ ដោយក្រុមប្រឆាំងពុទ្ធសាសនា ។ ប្រវត្តិសាស្ត្របានប្រាប់ថា អធិរាជមោក្ខាល(Mughal) ឈ្មោះហ៊្វូម៉ាយុន (Humayun) បានភៀសព្រះកាយទៅជ្រកនៅទីនោះ ពេលទ្រង់រត់គេចចេញពីការដេញតាមចាប់ របស់ហ្សេរហ្សាហសូរីហ្វូរី (Shershah Suri'sfury) ។ ដើម្បីរំលឹកដល់ព្រឹត្តិការណ៍នោះ រាជបុត្ររបស់អធិរាជហ៊្វូម៉ា

យុន ឈ្មោះអក្កបា ក្រោយមកទ្រង់បានទទួលតំណែងជាអធិរាជ ស្នងតំណែងបិតាមក ទ្រង់បានកសាងស្តូបអដ្ឋកោណនោះឡើង នៅលើទីខ្ពស់នោះឯង ។ ចំណែកកំពូលអដ្ឋកោណខាងលើ គឺជាស្តូបមូគ្គាល (Mughal) ដែលកសាងដោយគោវាដ្ឋាន(Govardhan) កូនប្រុសរបស់រាជាតូទារមលៈ (Raja Todarmal) ក្នុងឆ្នាំ១៥៨៨ ខណៈដែលគាត់កាន់តំណែងជាអភិបាលរដ្ឋ ក្រោមការត្រួតត្រារបស់អធិរាជអក្កបា ។ មានសិលាចារិក ដែលឆ្លាក់លើថ្មរលោងមួយផ្ទាំង នៅលើផ្លូវចូលពីខាងជើងនៃស្តូបនោះ បានរៀបរាប់ដូចខាងក្រោមនេះ

> "ស្តេចហ៊ូម៉ាយុន ជាព្រះរាជាទី៧, ដែលទ្រង់គង់នៅលើស្ថានសួគ៌ ទ្រង់បន្ទាបព្រះកាយចុះមក ហើយគង់នៅទីនេះពេញមួយថ្ងៃ ។ ដោយហេតុនេះ ការកើនឡើងនូវភាពរុងរឿងនៃព្រះសុរិយា, ព្រះរាជាអក្កបា ជាព្រះរាជបុត្ររបស់ព្រះអង្គ និងជាអ្នកបំរើដ៏ទន់ខ្សោយម្នាក់ សម្រេចព្រះទ័យកសាងស្តូបនេះឡើង ដែលមានកំពូលខ្ពស់ ត្រដែតទល់មេឃ នៅក្នុងឆ្នាំ ៩៩៦ អ.ហ. ដែលជាស្តូបដ៏ល្អបំផុត" ។

បើយើងឡើងទៅដល់កំពូលខាងលើ ហើយសម្លឹងមើលទៅខាងក្រៅតាមបង្អួចតូចៗ យើងពិតជាមានអារម្មណ៍រីករាយមិនខាន ដោយមើលឃើញនូវទេសភាពដ៏ស្រស់ត្រកាល នៃវាលស្រែល្វឹងល្វើយ ។ នៅវេទិកាឥដ្ឋខាងមុខស្តូបមានដោតទង់ជ័យខ្ពស់ទៅលើ គឺជាកន្លែងដែលអ្នកភូមិសម្លាប់ពពែ ដើម្បីបូជាយញ្ញដល់រូបសំណាកឱមការវីរៈ ដែលតម្កល់នៅទីនោះ ។

ការជីកកាយរបស់ក្រុមបុរាណវិទ្យា ជុំវិញបរិវេណស្តូបនោះ មិនបានជួបប្រទះឃើញសិលាចារិកណាមួយឡើយ មកទល់ពេលនេះ តែគេបានប្រទះឃើញរូបបដិមាខ្លះៗដែរ ដូចជារូបព្រះពុទ្ធកំពុងសម្តែងធម៌ទេសនា ដែលមានប្រវែង០,៩៥ម៉ែត្រ គង់លើរតនបល្ល័ង្កកំពស់០.៥០ម៉ែត្រ ។ នៅខាងមុខត្រង់កណ្តាលមានរូបសត្វប្រើសមួយគូ និងធម្មចក្រ ដែលបង្ហាញពីកម្លាំងព្រះធម៌ ។ រូបបដិមាទាំងអស់នោះ ត្រូវបានស្លាបនាឡើងពីថ្មតាមរចនាបថគុប្តៈ ។ មានរូបបដិមាអវលោកិតេស្វរៈ ទ្រូវរូបបដិមាព្រះពុទ្ធអមិតាភា នៅលើព្រះកេសផង ។



ចូកក្ខណ្ឌី នៅសារនាថ ជាកន្លែងដែលព្រះពុទ្ធបានជួបបញ្ចវគ្គិយភិក្ខុជាដំបូង



មូលគន្ធកុដិដើម កសាងត្រង់កន្លែងដែលព្រះពុទ្ធគង់ចាំវស្សាទី១ និងជាកន្លែងប្រកាសបង្កើតសហគមន៍សង្ឃ និងចេញផ្សាយសាសនា

# មូលគន្ធកុដិ

មូលគន្ធកុដិគឺជាកុដិដែលព្រះសម្មាសម្ពុទ្ធ ទ្រង់បានគង់ចាំព្រះវស្សា លើកដំបូងបំផុត បន្ទាប់ពីបានសម្ដែងធម៌ទេសនា ប្រោសបញ្ចវគ្គីយភិក្ខុទាំងប្រាំអង្គរួចមក ។ មូលគន្ធកុដិស្ថិតនៅក្បែរកុដិ របស់បញ្ចវគ្គីយភិក្ខុទាំងប្រាំអង្គ សំណង់នេះបែរមុខទៅទិសខាងកើត១៨.២៩ម៉ែត្រ ស្ថិតនៅខាងជើងធម្មរាជិកស្តូប ។ សម័យពុទ្ធកាល កុដិដែលព្រះពុទ្ធគង់អាស្រ័យនៅហៅថា “គន្ធកុដិ”. ប៉ុន្តែនៅឯសារនាថវិញ ហៅថា “មូលគន្ធកុដិ” ។ ភិក្ខុធម្មរក្ខិតៈបានអះអាងយ៉ាងសាមញ្ញថា បានជាហៅថាមូលគន្ធកុដិដូច្នេះ ពីព្រោះព្រះពុទ្ធបានគង់នៅក្នុងកុដិនោះ ហើយបានសម្តែងធម្មចក្កប្បវត្តនសូត្រ នៅក្នុងវស្សាដំបូងបំផុត ។

ហ៊្វិន-ត្សាង អ្នកប្រវត្តិវិទូចិនបានធ្វើដំណើរទៅដល់ទីនោះ បានកត់ត្រាទុកថា មូលគន្ធកុដិមានកំពស់៦៥.៩៦ម៉ែត្រ ។ មូលគន្ធកុដិមានគ្រឹះខាងក្រោមនិងជញ្ជាំងធំទូលាយ បានបង្ហាញពីភាពធំទូលាយនិងភាពល្អឥតខ្ចោះ របស់សំណង់នោះ ។ សំណង់នោះសង់ពីឥដ្ឋនិងថ្ម មកដល់សម័យគុប្តៈ មូលគន្ធកុដិត្រូវបានគេកសាងជញ្ជាំងបន្ថែម ត្រង់កណ្តាលដើម្បីជួយទ្រដល់ដំបូល ខាងលើឲ្យបានកាន់តែរឹងមាំ ។

ព្រះរាជាអង្គណាដែលគោរពពុទ្ធសាសនា ទ្រង់បានគ្រប់គ្រងដែនដីឥណ្ឌា ទ្រង់មានរស្មីភ្លឺត្រចះដូចជាបក្សីមាស ។ ចំណែកព្រះរាជាដែលមិនគោរពពុទ្ធសាសនា ទ្រង់មិនមានព្រះទ័យរីករាយឡើយ, ពេលដែលស្ដេចមេហាមូដ-គ្អា

ស្សាណាវី គ្រងអំណាចក្រុងពារាណសី ព្រះអង្គបានបំផ្លាញចោល នូវសំណង់ពុទ្ធសាសនា ដ៏មានតម្លៃនោះអស់រលីងគ្មានសល់ ។ ពួកព្រហ្មញ្ញសាសនា បានឆក់ឱកាសនោះ ចាប់យកទីតាំងពុទ្ធសាសនា ធ្វើជាទីតាំងរបស់ខ្លួនគេតរៀងមក និងបានធ្វើការប្រឆាំងមកលើពុទ្ធសាសនា យ៉ាងខ្លាំងក្លាទៀតផង ។

មូលគន្ធកុដិត្រូវបានជួសជុលឡើងវិញ ដោយព្រះអគ្គមហេសីកុមារទេវី ក្នុងខណៈដែលស្វាមីរបស់ព្រះនាង បានឡើងគ្រងរាជសម្បត្តិ (ឆ្នាំ១១១៤-១១៥៤) ។ ព្រះអគ្គមហេសី ទ្រង់បានកសាងនូវព្រះពុទ្ធរូបដ៏ធំមួយអង្គ គង់សម្តែងធម៌ទេសនាពីថ្មដ៏ល្អបំផុត ដែលជាស្នាដៃឯកគ្មានពីររបស់វិចិត្រករ ក្នុងសម័យនោះ ។

# អនាគារិកធម្មបាល

អនាគារិកធម្មបាល ជាឈ្មោះជនជាតិស្រីលង្កាម្នាក់ ភេទប្រុស បានធ្វើធម្មយាត្រាទៅកាន់ប្រទេសឥណ្ឌា ដើម្បីថ្វាយបង្គំពុទ្ធស្ថាន កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ១៨៩១ ។ ពេលនោះគាត់បានមើលឃើញមូលគន្ធកុដិ ជាកុដិដែលព្រះពុទ្ធបរមគ្រូគង់ប្រថាប់នៅ ត្រូវបានគេបោះបង់ចោល នៅក្នុងតំបន់សារនាថ ស្ថិតនៅក្នុងភាពបាក់បែកទ្រុឌទ្រោម គួរឲ្យសង្វេគពន់ពេក និងគ្មានការយកចិត្តទុកដាក់ ថែរក្សាការពារឡើយ មានតែសត្វជ្រូកព្រៃដើររកកាយចំណី ក្រៅពីនោះមានអារាមរបស់សាសនាអចេលតែប៉ុណ្ណោះ ។ សំណង់ជាទីគោរពនេះ ត្រូវបាន

ស្តេចទេវ័នជគាសិង្ហ បានវាយបំបែករុះរើ យកឥដ្ឋនិងថ្មនៃមូលគន្ធកុដិទៅកសាងសំណង់ផ្សារទៅវិញ សូម្បីតែធម្មរាជិកស្តូប ដែលកសាងឡើងដោយព្រះបាទធម្មាសោក ក៏ត្រូវបានស្តេចអង្គនោះ បញ្ជាឲ្យគេវាយបំបែកស្ទើរតែអស់រលីងដែរ ។ ម៉្យាងទៀត មានគ្រោះធម្មជាតិទឹកជំនន់ដ៏ធំមួយបានកើតឡើង ហើយបានបំផ្លាញសំណង់នោះ ខូចអស់មួយផ្នែកធំ ហើយសំណង់ដែលនៅសេសសល់ ត្រូវបានបោះបង់ចោល អស់រយៈពេល៧០០ឆ្នាំមកទៀត ។ អនាគារិកធម្មបាលមានការតូចចិត្តយ៉ាងខ្លាំង ដោយមើលឃើញពុទ្ធស្ថានមានសភាពបែបនេះ, គាត់បានប្តេជ្ញាចិត្តយ៉ាងមាំថា នឹងជួសជុលពុទ្ធស្ថាននេះឲ្យបានល្អឡើងវិញ តាមដែលអាចធ្វើទៅបាន ។ គាត់បានបង្កើតឡើងនូវសមាគមមួយ មានឈ្មោះថា “សមាគមមហាពោធិ” (Maha Bodhi Society) ដើម្បីទាមទារយកមកវិញនូវតំបន់ពុទ្ធស្ថានប្រវត្តិសាស្ត្រ ពីការកាន់កាប់ដោយសាសនាហិណ្ឌូ តាមរយៈរដ្ឋាភិបាលឥណ្ឌា មកជារបស់ពុទ្ធសាសនាវិញ ព្រមទាំងប្រមូលថវិកាពីសប្បុរសជនដើម្បីគាស់កាយរកស្តូបនិងសំណង់បាក់បែក ធ្វើការជួសជុលឡើងវិញ ។ អនាគារិកធម្មបាលបានបូជាជីវិតរបស់គាត់ ក្នុងការកសាងឡើងវិញ នូវពុទ្ធស្ថានទាំងអស់ ដែលមាននៅក្នុងប្រទេសឥណ្ឌា, គាត់ប្រាថ្នាឲ្យបានកើតឡើងវិញ នៅក្នុងប្រទេសឥណ្ឌា២៥ជាតិទៀត និងប្រាថ្នាជាពុទ្ធភូមិទៅអនាគត ។

# មូលគន្ធកុដិថ្មី

អនាគារិកធម្មបាល បានខិតខំប្រឹងប្រែងឥតឈប់ឈរ រៀបចំឯកសារសុំច្បាប់អនុញ្ញាតពីរដ្ឋាភិបាលឥណ្ឌា ដើម្បីជួសជុលពុទ្ធស្ថាននោះឡើងវិញ ។ ឆ្នាំ១៩២២ នៅពេលដែលលោក ហ.អ. បុត្លឺ (H. I. Butler) កាន់តំណែងជាអភិបាលរដ្ឋឧត្តរប្រទេស, មូលគន្ធកុដិនោះ ទើបតែកសាងបានគ្រឹះខាងក្រោមប៉ុណ្ណោះ ក៏ត្រូវជាប់គាំងអស់ជាងបួនឆ្នាំ ដោយសារតែមានការជំទាស់ពីរដ្ឋាភិបាលឥណ្ឌាពេលនោះ, ទីបំផុតលោកចន-ម៉ាក្សាល (John Marshal) អគ្គនាយក នៃនាយកដ្ឋានបុរាណវិទ្យា យល់ព្រមឲ្យកសាងមូលគន្ធកុដិបន្តទៅទៀត ។ ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៣១ ព្រះសារីរិកធាតុរបស់ព្រះពុទ្ធបរមគ្រូ ត្រូវបាននាំមកតម្កល់ទុកក្នុងមូលគន្ធកុដិថ្មីនេះ ។ ព្រះសារីរិកធាតុដែលបាននាំមកតម្កល់ទីនោះ ត្រូវបានក្រុមបុរាណវិទូ គាស់កាយរកឃើញនៅទីក្រុងតក្កសិលា ប្រទេសប៉ាគីស្ថាន ។ សំណង់របស់ពុទ្ធសាសនាថ្មីនេះ មានឈ្មោះថា “មូលគន្ធកុដិ” កសាងឡើងដោយអនាគារិកធម្មបាលឧបាសក ស្ថិតនៅជាប់នឹងមូលគន្ធកុដិចាស់សម្រាប់តម្កល់ព្រះសារីរិកធាតុព្រះពុទ្ធបរមគ្រូ ។ នៅសារនាថមានរៀបចំពិធីបុណ្យដង្ហែព្រះសារីរិកធាតុ ប្រទក្សិណទីក្រុងដោយក្បួនដំរីរៀងរាល់ឆ្នាំ នៅក្នុងថ្ងៃ១៥កើត ខែកត្តិក ដែលមានពុទ្ធបរិស័ទទាំងព្រះសង្ឃ និងគ្រហស្ថមកពីប្រទេសនានា លើពិភពលោកចូលរួមដង្ហែយ៉ាងច្រើនកុះករ ។

នៅខាងស្តាំនៃមូលគន្ធកុដិថ្មី មានដើមពោធិ៍មួយដើមយ៉ាងធំបែកមែកសាខា ជាពូជដើមពោធិព្រឹក្សដែលនាំមកពីអនុរាធបុរៈ ប្រទេសស្រីលង្កា ដោយអនាគារិកធម្មបាល កាលពីឆ្នាំ១៩៣១, ស្ថិតនៅជាប់នឹងដើមពោធិ៍ គឺជាកំផែងថ្មព័ទ្ធជុំវិញដើមពោធិ៍នោះ កសាងឡើងដោយសមាគមពុទ្ធបរិស័ទ មកពីប្រទេសភូមា នៅក្នុងឆ្នាំ១៩៨៩ ។ នៅជិតដើមពោធិ៍មានរូបបដិមា ព្រះពុទ្ធសម្តែងបឋមទេសនាធម្មចក្ក និងមានបញ្ចវគ្គិយភិក្ខុទាំងប្រាំអង្គ កំពុងអង្គុយស្តាប់ធម៌ដោយគោរព ។




មូលគន្ធកុដិថ្មីចាប់កសាងនៅឆ្នាំ១៩២២ ចប់ជាស្ថាបពរនៅឆ្នាំ១៩៣១ ដោយអនាគារិកធម្មបាល ជាជនជាតិស្រីលង្កា សំរាប់តម្កល់ព្រះសារីរិកធាតុព្រះពុទ្ធបរមគ្រូ ។

# សំណង់ពុទ្ធសាសនាប្រទេសនានា
# និងសំណង់សាសនាដទៃ នៅសារនាថ

## វត្តពុទ្ធសាសនាភូមា

វត្តរបស់ព្រះពុទ្ធសាសនាភូមា ឈ្មោះមហាវិជិតវិសីមា ឬហៅថា វត្តភូមា កសាងឡើងនៅលើផ្ទៃដីទំនាបមួយកន្លែង ស្ថិតនៅខាងលិចមូលគន្ធកុដិ ។ អារាមនេះកសាងឡើងនៅក្នុងឆ្នាំ១៩៣៤ ដោយលោកស្រី ដាវរាយូ (Daw Ryu) និងកូនស្រីរបស់គាត់ឈ្មោះ ម៉ាថាន់យុន និង ដាវ-ហ្គោម ព្រមទាំងកូនប្រុសឈ្មោះ មួង ហ្លាខេង មកពីទីក្រុងរង់ហ្គោន ប្រទេសភូមា ។ វត្តនេះមានកុដិជាច្រើនសម្រាប់ព្រះសង្ឃគង់ សង់ពីថ្ម២-៣ជាន់ មានហោត្រ័យ សាលាប្រជុំ ។ល។ សង់ឡើងក្នុងទម្រង់រចនាបថភូមា ។ ក្រៅពីនោះមានរូបព្រះពុទ្ធអង្គធំ ទ្រង់ផ្ទុំសាងពីថ្មម៉ាប និងរូបអគ្គសាវ័កឆ្វេង-ស្តាំទាំងពីរអង្គ សាងឡើងដោយសប្បុរសជនជាតិភូមា ។ នៅខាងមុខវត្តមានអាគារបណ្ណាល័យធំមួយឈ្មោះថា បណ្ណាល័យសទ្ធម្មរង្សី កសាងដោយលោក អ៊ូស្វីវីន និងភរិយា នៅទីធ្លាខាងមុខបណ្ណាល័យ មានព្រះពុទ្ធធំមួយអង្គ គង់នៅក្រោមឆ័ត្រកសាងនៅឆ្នាំ១៩៩៤ ។

## វត្តពុទ្ធសាសនាកូរ៉េ

វត្តព្រះពុទ្ធសាសនាកូរ៉េ មានចម្ងាយ៣៥០ម៉ែត្រ ខាងជើងផ្លូវត្រឡែងកែងធំក្បែរមហាពោធិ, កសាងដោយវិទ្យាល័យអន្តរជាតិចនគីន (Inter

College John Kinz) និងស្ថិតនៅក្រោមការគ្រប់គ្រងព្រះសង្ឃឈ្មោះពិសុទ្ធ។ វត្តនេះត្រូវបានបើកសម្ពោធជាផ្លូវការ នៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ១៩៩៦ ស្ថិតនៅលើផ្ទៃដី០.៦១ហិកតា ។ ផ្លូវធំសម្រាប់ចូលទៅវត្តនៅទិសខាងត្បូង, នៅខាងក្នុងវិហារធំ មានព្រះពុទ្ធរូបដ៏ធំមួយអង្គសាងពីថ្មម៉ាប ។

## វត្តពុទ្ធសាសនាចិន

ដើរប្រហែល២០០ម៉ែត្រ ឆ្ពោះទៅទិសខាងកើត ជិតស្ថានីយ៍រថភ្លើងនៅខាងឆ្វេងដៃ មានវត្តពុទ្ធសាសនាចិនមួយ ដែលបានកសាងឡើងនៅក្នុងឆ្នាំ១៩៣៩ ដោយព្រះតេជគុណ តេ-យុ ជាសិស្សរបស់សម្ដេចសង្ឃតៅកៃ, ជាចៅអធិការនៅទីក្រុងប៉េកាំង ប្រទេសចិន និងលោក ហ្វា-យួនត្សូ ប្រធានសមាគមពុទ្ធសាសនាអាស៊ីបូព៌ា, លោកប្រធានធនាគារនៅក្រុងសាំងហ្គាពួរ ឈ្មោះលី-ឆុងសេង ជាអ្នកចំណាយធនធានយ៉ាងច្រើន ។ ក្លោងទ្វារនិងរបងវត្តកសាងឡើងនៅឆ្នាំ១៩៥២ ដោយព្រះតេជគុណ ប៉ូ-ចៅ និងព្រះតេជគុណចេវ-ត្សៅ ជាព្រះសង្ឃជាន់ខ្ពស់ ដែលក្រោយមកបានទទួលតំណែងបន្តពីព្រះតេជគុណ តេ-យុ ។ ថវិកាសម្រាប់ការកសាងវត្តបន្ថែមទៀត គឺបានមកពីការជ្រះថ្លារបស់ពុទ្ធបរិស័ទចិន នៅប្រទេសនានាលើពិភពលោក ។ សំណង់នៅក្នុងវត្ត មានសាលាប្រជុំធំមួយមានទម្រង់បួនជ្រុងស្មើ មានព្រះពុទ្ធរូបសាងពីថ្មម៉ាបយ៉ាងស្អាត គង់នៅត្រង់កណ្ដាល ។ ព្រះពុទ្ធរូបនេះឆ្លាក់នៅប្រទេសភូមា ដែលបានបង្ហាញចេញនូវក្បូរក្បាច់សិល្បៈភូមា ។

## វត្តពុទ្ធសាសនាជប៉ុន និកាយនិជីហុកាស៊ុំសានហ៊ុរីននីជី

ចម្ងាយប្រហែល១០០ម៉ែត្រ នៅខាងលិចវិហារសារនាថ របស់សាសនាជេន, សមាគមឥណ្ឌា-ជប៉ុនឈ្មោះធម្មចក្រ បានកសាងវត្តពុទ្ធសាសនាមួយនៅលើផ្ទៃដីទំហំ២៥០០ម៉ែត្រក្រឡា ដែលមានឈ្មោះថាវត្តឥណ្ឌា-ជប៉ុន ។ អារាមនេះបានរៀបចំពិធីបញ្ចុះបឋមសិលា នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៨៦ ។ ការសង់សំណង់ក្នុងវត្តយកតាមរនាបថ និងក្បូរក្បាច់សិល្បៈវត្តជប៉ុនទាំងស្រុង ។ គ្រឿងនិងសម្ភារៈសំខាន់ៗឯទៀតៗ នាំមកពីប្រទេសជប៉ុន ។ តម្លៃនៃការសាងសង់វត្តនេះអស់ជាង១០លានរូពី ហើយបានសម្ពោធបើកឲ្យប្រើប្រាស់ ជាផ្លូវការនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៩២ ។ នៅក្នុងវិហារធំ មានតម្កល់រូបព្រះពុទ្ធគង់សមាធិ និងមានរូបព្រះពោធិសត្វជាច្រើនអង្គទៀត គង់តម្រៀបជាជួរ ។ ងាកទៅទិសខាងលិចបន្តិច មានផ្លូវមួយឆ្ពោះទៅកាន់ផ្លូវថ្នល់ធំ នៅប្រហែល១០០ម៉ែត្រ ខាងត្បូងគឺជាវត្តពុទ្ធសាសនាទីបេ ។

## វត្តពុទ្ធសាសនាទីបេ

នៅក្នុងឆ្នាំ១៩៩៥ ក្រោមអធិបតីភាព នៃព្រះសង្ឃឃោសេឡាម៉ា(Go shelama) ជាព្រះសង្ឃទីបេ ដែលបានភៀសខ្លួនដោយសង្គ្រាម បានដឹកនាំការកសាងវត្តនេះឡើង ។ ព្រះពុទ្ធរូបមួយអង្គដែលធំជាងគេបង្អស់ នៅក្នុងតំបន់សារនាថ ត្រូវបានកសាងឡើងនៅក្នុងវត្តនេះ និងមានរូបបដិមា៩អង្គទៀត ដែល

ក្នុងនោះមានរូប២ជារូបបដិមាព្រះពុទ្ធ ។ រូបពីរទៀតជាសាវ័កព្រះអង្គ មួយជារូបបដិមាព្រះតារា មួយទៀតជារូបបដិមាព្រះសង្ឃត្សុងកប្បៈរបស់ទីបេ និងពីរទៀតជារូបបដិមាសាវ័ក របស់ព្រះសង្ឃអង្គនោះ ។ ព្រះសង្ឃ នាមត្សុង-កប្បៈ ជាសង្ឃនិកាយគេលុប្បៈនៃពុទ្ធសាសនាទីបេ ។ មាននិកាយចំនួន៣ ដែលធ្លាប់មានឈ្មោះល្បីគឺ និកាយនីយិនគបៈ Nyingapa), និកាយសក្យៈ(Shakya) និងនិកាយកគ្យុដប(Kagyudpa) ។ ជនជាតិទីបេជាច្រើនពាន់នាក់ ទាំងបព្វជិតទាំងគ្រហស្ថនៃនិកាយទាំងនោះ បានទៅនមស្សការគោរពបូជា ព្រះពុទ្ធរូបនៅក្នុងវត្តនេះជារៀងរាល់ឆ្នាំ ។ នៅក្នុងវិហារមានតម្កល់ទុក នូវគម្ពីរពុទ្ធសាសនាសំខាន់ចំនួន១៥០ ហើយដែលបានបកប្រែជាភាសាទីបេ នៅក្នុងសតវត្សទី៧ ទៅសតវត្សទី៩ ។ មានរបស់ដែលធ្វើឲ្យភ្ញាក់ផ្អើលមួយទៀត នៅក្នុងវត្តទីបេ គឺរូបគំនូរដែលគូរនៅលើក្រណាត់សំពត់ ដែលគេបានដាក់ព្យួរតាមជញ្ជាំងវិហារ ។ ផ្ទាំងរូបគំនូរក្រណាត់សំពត់នេះ មានអាយុជាច្រើនរយឆ្នាំមកហើយ ប៉ុន្តែនៅមានពណ៌ស្រស់ល្អឆើត ។

## វត្តខ្មែរក្រុងពារាណសី

វត្តខ្មែរក្រុងពារាណសី ស្ថិតនៅចម្ងាយប្រហែល៥០០ម៉ែត្រ ពីទីមូលគន្ធកុដិថ្មី ដែលបានកសាងឡើងនៅឆ្នាំង២០០៧ ដោយព្រះសង្ឃខ្មែរ ដែលបាននិមន្តសិក្សារៀនសូត្រនៅប្រទេសឥណ្ឌា ។ ព្រះតេជគុណ សែម ប៊ុច ជាប្រធាននៃគណៈកម្មការសាងសង់វត្ត ហើយដែលមានព្រះតេជគុណ បណ្ឌិត ញ៉ែម

គឺមតេង ជាឧត្តមទីប្រឹក្សាផ្តល់យោបល់ និងជួយណែនាំក្នុងការកសាងវត្តខ្មែរក្រុងពារាណសីនេះ ។ មានសប្បុរសជនខ្មែរនៅប្រទេសកម្ពុជា ប្រទេសបារាំង អាមេរិកអូស្ត្រាលី កាណាដា ដែលបានធ្វើធម្មយាត្រាទៅនមស្សការពុទ្ធស្ថាន នៅប្រទេសឥណ្ឌា មានសទ្ធាជ្រះថ្លាចូលបច្ច័យក្នុងការកសាង ក្នុងនោះក៏បានបច្ច័យដែលបានមកពីពិធីបុណ្យផ្កា ដែលបានធ្វើឡើងនៅប្រទេកម្ពុជាផងដែរ ។ មកដល់សព្វថ្ងៃ វត្តខ្មែរក្រុងពារាណសី បានក្លាយទៅជាអារាមពុទ្ធសាសនាខ្មែរដ៏ធំមួយគួរឲ្យគោរពនិងឲ្យជ្រះថ្លា ។

## វត្តពុទ្ធសាសនាថៃ

ប្រហែលជា៣៥០ម៉ែត្រនៅខាងជើង តាមផ្លូវទៅកាន់ចូក្ខណ្ឌីស្តូប គឺជាវត្តរបស់ពុទ្ធសាសនាថៃ ដែលបានកសាងឡើង ក្រោមការដឹកនាំរបស់ព្រះគ្រូប្រាកាសមាធិគុណ ជាអ្នកដឹកនាំនៃក្រុមធម្មយាត្រា ទៅកាន់ក្រុងសារនាថ ក្នុងឆ្នាំ១៩៦៩ ដើម្បីនមស្សការពុទ្ធស្ថាន ដែលមាននៅក្នុងប្រទេសឥណ្ឌា ។ ព្រះគ្រូប្រាកាសមាធិគុណ បានចាប់អារម្មណ៍យ៉ាងក្រៃលែង លើការកសាងវត្តថៃ នៅក្នុងពុទ្ធស្ថានសារនាថនេះ ហើយបានប្រកាសបញ្ចុះបញ្ចូលញាតិញោម ដើម្បីជួយឧបត្ថម្ភដល់ការកសាងវត្ត ។ នៅថ្ងៃទី២៧ មករា ឆ្នាំ១៩៦៩ បានបង្កើតគណៈកម្មការសមាគមមួយ ដើម្បីស្វែងរកថវិកាកសាងវត្ត, ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៧៤ បានបញ្ចុះបឋមសិលា, ថ្ងៃទី១០ខែកុម្ភៈ ឆ្នាំ១៩៧៦ បានប្រកាសបើកវត្តថៃជាផ្លូវការ ។ នៅឆ្នាំ១៩៩៣ វត្តពុទ្ធសាសនាថេរវាទថៃមួយ បានកើតឡើង

ពេញលក្ខណៈ ដែលមានព្រះពុទ្ធរូបក្នុងទម្រង់ជាភូមិស្បៈមុទ្រៈ បែរព្រះភ័ក្ត្រទៅទិសខាងកើត ជានិមិត្តរូបនៃព្រះពុទ្ធផ្ចាញ់មារ មានសាលាធំមួយជាកន្លែងប្រតិបត្តិសមាធិ ។ វត្តនេះបង្កើតមូលនិធិមួយមានឈ្មោះថា មូលនិធិម្រឹគទាយវ័នមហាវិហារ ដែលមានទីតាំងនៅទីក្រុងបាំងកក ប្រទេសថៃ ។

## ម្រិគទាយវ័ន

ដូចបានបញ្ជាក់រួចមកខ្លះហើយ តំបន់សារនាថត្រូវបានគេហៅថា ម្រិគទាយវ័ន (ព្រៃឲ្យអភ័យដល់សត្វម្រិគ) ដែលបានបកស្រាយប្រាប់ថា មានសត្វម្រិគជាច្រើនរយក្បាល រសើនៅក្នុងសម័យពុទ្ធកាល ។ ម្រឹគទាយវ័នក្នុងពេលក្នុងពេលបច្ចុប្បន្ននេះ ត្រូវបានបង្កើតឡើង ដើម្បីទុកជាទីរលឹក ដល់កន្លែងម្រឹគទាយវ័នពីបូរាណ ។ សត្វម្រឹគមួយចំនួន នៅតែត្រូវបានអភិរក្សនៅក្នុងព្រៃម្រឹគទាយវ័ននោះ ដោយរដ្ឋាភិបាលនៃរដ្ឋឧត្តរប្រទេស ។ ឧទ្យានម្រឹគទាយវ័ននេះត្រូវបានបង្កើតឡើង ក្នុងឱកាសបុណ្យខួបទី២៥០០ នៃថ្ងៃព្រះពុទ្ធបរិនិព្វាន ។ ឧទ្យាននេះមានទំហំផ្ទៃដីបួនហិកតា ស្ថិតនៅបណ្ដោយស្ទឹង ដែលមានទឹកដក់ ។

## វិហារជេនសាសនាឈ្មោះជម្ពូចក្រា

ចម្ងាយ២៣២ម៉ែត្រពីកើតទៅលិច គឺមានសំណង់មួយស្ថិតនៅត្រង់កណ្ដាល ។ បូជនិយស្ថាននេះជាអំណោយរបស់ព្រះនាងកុមារីទេវី ជាព្រះអគ្គមហេសីរបស់ស្ដេចគោវិន្ទចន្ទ្រ នៃដែនកាសី (ឆ្នាំ១១១៤-១១៥៤) ដែលជា

ព្រះរាជាមានសេចក្តីជ្រះថ្លា ចំពោះពុទ្ធសាសនា ទ្រង់បានកសាងកុដិ សាលាវិហារ ហោត្រ័យ ថ្វាយព្រះសង្ឃយ៉ាងច្រើន តែសព្វថ្ងៃរបស់ទាំងនោះបានបាត់បង់អស់ទៅហើយ ។ វត្តនេះមានក្លោងទ្វារចូលពីរ គឺនៅទិសខាងកើត និងទិសខាងលិច ដែលមានចម្ងាយពីគ្នា៨៨,៩៥ម៉ែត្រ ។

## វត្តពុទ្ធសាសនាជេន (សាសនាអចេល)

ស្ថិតនៅជិតបង្ហើយនឹងធម្មេកស្តូប គឺជាវត្តសាសនាអចេល ដែលបានកសាងឡើង នៅក្នុងឆ្នាំ១៨២៤ ដើម្បីឧទ្ទិសដល់កំណើតនៃជេនតិរថង្ករ:ទី១១ ឈ្មោះស្រីយ័មសានាថ មានរូបបដិមាដ៏ធំមហិមា ត្រូវបានគេដាក់តម្កល់នៅទីនោះ ប៉ែកខាងក្នុងវិហារមានរៀបចំ ដាក់តាំងរូបគំនូរគួរឲ្យចាប់អារម្មណ៍ក្រៃលែង ដែលពណ៌នាពីជីវប្រវត្តិនៃព្រះមហាវីរ: ជាសាស្តាចារ្យនៃសាសនានេះ ។ ទីកន្លែងវត្តបច្ចុប្បន្ននេះ គេជឿថាជាផ្នែកមួយនៃភូមិសិមហាបុរ:ពីអតីតកាល ដែលប្រៀបធៀបទៅនឹងភូមិ ដែលមានឈ្មោះដូចគ្នានេះ មានចម្ងាយ១៥០០ម៉ែត្រពីទីនេះ ។

## រូបសំណាក់កសិជ័កបុរិតិរថ:

នៅក្នុងឆ្នាំ១៨០០ អាចារ្យកុសលចន្ទ្រ:សុរិយ: មានកសាងវិហារសាសនាជេន នៅក្នុងភូមិហិរាម័នបុរ: តាមអក្សរដែលបានឆ្លាក់នៅត្រង់ក្លោងទ្វារ ។ សព្វថ្ងៃនេះអក្សរនោះ ក៏រលុបរលាយបាត់ទៅវិញអស់ហើយ ។ ភូមិហិរាម័នបុរ:

ស្ថិតនៅទិសអគ្នេយ៍ចម្ងាយ១៥០០ម៉ែត្រ ពីទីក្រុងសារនាថ ។ រូបបដិមារបស់ស្រីយ័មសានាថ (Shreyamsanatha) ។ រូបបដិមារបស់ស្រីយ័មសានាថ ស្ថិតនៅក្នុងទម្រង់មូលនាយក-ជិ (Mulanayaka-Ji) តម្កល់នៅទីនោះ, នៅជ្រុងទាំងបួនខាងក្នុងវិហារធំ មានរូបគំនូរនិមិត្តរូបនៃសិល្បៈវិនាដកម្មទាំងបួន របស់ព្រះអាទិទេព ។ មានអាគារធំសម្រាប់អ្នកចូលទៅគោរពបូជា ដែលត្រូវការស្នាក់នៅ ។ មានដើមឈើខ្ពស់ៗជាច្រើន មានម្លប់ត្រជាក់ មានរុក្ខជាតិផ្កាជាច្រើនប្រភេទ និងសួនច្បារលំអព័ទ្ធជុំវិញវិហារធំ គួរឲ្យរីករាយក្រៃលែង ។

## វិហារព្រះសិវៈ ឈ្មោះសារង្គនាថ

ចេញពីវត្តចិនដើរទៅមុខត្រង់ឆ្ពោះទៅស្ថានីយ៍រថភ្លើង មុននឹងទៅដល់ប្រហែល១៥០ម៉ែត្រ ត្រូវងាកមើលទៅស្តាំ និងបានឃើញនៅលើទីទួលខ្ពស់ គឺជាវត្តដែលគេកសាងឡើង ដើម្បីឧទ្ទិសចំពោះព្រះសិវៈ ដែលព្រះអង្គស្ថិតក្នុងរូបជាសត្វប្រើសអាទិទេព ដែលយើងបានស្គាល់រួចមកហើយ ឈ្មោះសារាង្គនាថ ។ នៅក្នុងវិហារដដែលនោះ មានរូបលិង្គមួយមានឈ្មោះថាសោភនាថ ។ នៅជ្រុងខាងកើតវត្តមានស្រះទឹកធំមួយ មានឈូកដុះពាសពេញ ដែលមានផ្ការីកស្គុះស្គាយ គេមានជំនឿថាវត្តនេះកសាងឡើងនៅលើទីស្តូបបុរាណ នៃសាសនាសៃវីតេ (Shaivite cult) ដែលបានបង្កើតឡើងនៅក្នុងអតីតកាល ។ នៅក្នុងខែស្រាពណ៍ ប្រជាជនដែលមានផ្ទះនៅជុំវិញតែងបានទៅជួបជុំគ្នា ហើយប្រារព្ធពិធីបុណ្យយ៉ាងសប្បាយរីករាយ ។ ទីអារាមនោះមានបរិស្ថានស្រស់បំព្រង ដែល

អាចទាក់ទាញមនុស្សឲ្យជ្រះថ្លា ចូលទៅគោរពបូជាថ្វាយផ្កានិងបង្អែមជាដើម ចំពោះសារង្គនាថ៕

# និញ្ញានបច្ចយោ ហោតុ



រូបព្រះពុទ្ធបដិមាថ្ម សម័យគន្ធារៈសវ.ទី២



កោដ្ឋព្រះសារីរិកធាតុ នៅសារមន្ទីរជាតិញូដែល្លី ប្រទេសឥណ្ឌា គាស់ចេញពីព្រះស្តូប
នៅក្រុងកបិលភ័ស្តុ




រូបថតអានុស្សាវរីយ៍ ពីឆ្វេង លោកសាស្ត្រាចារ្យ ប្រាក់ ព្រុំ,
ព្រះសុមេធវង្ស ញ៉ែម គឹមតេង, បណ្ឌិត សំ បេ ថតនៅសារនាថ